# ជំពូកទី ៤
# ទិសដៅការយុទ្ធសាស្ត្រ ឆ្នាំ២០០៦

## កិច្ចការពារព្រំដែន:

អាទិភាពនៃកិច្ចការពារជាតិដ៏សំខាន់ជាអាយុជីវិតមួយ នៅក្នុងចំណោមអាទិភាពទាំងឡាយដែលបានកំណត់នៅក្នុងជំពូក ៣ គឺការការពារព្រំដែនសីមារបស់ព្រះរាជាណាចក្រកម្ពុជា ។ នៅក្នុងកាលៈទេសៈដែលវិវាទព្រំដែន ការគំរាមកំហែងពីសំណាក់ឧក្រិដ្ឋកម្មឆ្លងកាត់ព្រំដែន និងអំពើភេរវកម្មអន្តរជាតិ ស្ថិតនៅជាកង្វល់នៅឡើយ ប្រទេសកម្ពុជាចាំបាច់ត្រូវពង្រឹងសមត្ថភាពការពារព្រំដែន ដើម្បីរក្សាឱ្យបាននូវសន្តិភាព និងស្ថិរភាពជាមួយប្រទេសជិតខាង និងដើម្បីធានានូវសន្តិសុខសំរាប់ប្រជាជាតិទាំងមូលផងដែរ ។ សមត្ថភាពរបស់កងកំលាំងការពារព្រំដែនត្រូវតែពង្រឹងបន្ថែមទៀត ជាពិសេសនិរន្តរភាពនៃវត្តមានរបស់កំលាំងនៅគ្រប់គោលដៅទាំងអស់ ជំនាញក្នុងការទប់ស្កាត់ការជ្រៀតចូលរបស់ភេរវកម្មអន្តរជាតិ និងឧក្រិដ្ឋកម្មឆ្លងដែន ការចល័តកំលាំង ការទាក់ទង ការប្រមូលពត៌មាន កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ជាដើម ។ ការពង្រឹងវត្តមានរបស់កំលាំងការពារព្រំដែន ពុំមែនមានន័យថាជាការប្រឈមមុខណាមួយនោះឡើយ ផ្ទុយទៅវិញការយល់ដឹង និងការគ្រប់គ្រង់សភាពការណ៍បានទាន់ពេលវេលា គឺជាកត្តាសំខាន់សំរាប់ដំណោះស្រាយជាវិជ្ជមាន និងការកសាងទំនុកទុកចិត្តនៅក្នុងតំបន់ ។ម្យ៉ាងវិញទៀត ទំនាក់ទំនងជាប្រចាំជាមួយដៃគូទាំងឡាយ នឹងបង្កើនទំនុកទុកចិត្ត និងសម្ព័ន្ធភាពល្អប្រសើរ ។

ការផ្លាស់ប្តូរកំលាំងការពារព្រំដែន គឺជាបញ្ហាសំខាន់ដែលត្រូវដោះស្រាយជាដំបូង ។ នៅក្នុងកាលៈទេសៈដែលរចនាសម្ព័ន្ធទំនាក់ទំនងនៅតាមតំបន់ព្រំដែនមានការខ្វះខាត គួបផ្សំនឹងឥទ្ធិពលធម្មជាតិនៅក្នុងតំបន់ អាចធ្វើឱ្យឆ្មាំការពារព្រំដែនមានការលំបាកនៅក្នុងការបំពេញភារកិច្ច និងមានការនឿយណាយ ។ ដូច្នេះ ទាមទារឱ្យមានការ

ផ្លាស់ប្តូរកំលាំងជាប្រចាំ ជាពិសេសធានាឱ្យបាននូវវត្តមានគ្រប់ពេលវេលាទាំងអស់ ។ បើសិនជាមានការចាំបាច់ កំលាំងតំបន់ប្រតិបត្តិការសឹករងរបស់យោធភូមិភាគនីមួយៗ អាចត្រូវយកទៅប្រើប្រាស់បន្ថែមសំរាប់ភារកិច្ចនេះ ។ ត្រូវគិតគូរឡើងវិញអំពីបញ្ហាឥទ្ធិពលភូមិសាស្ត្រ នៅក្នុងការដាក់វាយកងឯកភាពការពារព្រំដែនផងដែរ ឧទាហរណ៍ដូចជាតំបន់មួយចំនួនហាក់ដូចជាពុំចាំបាច់ឱ្យមានការដាក់ពង្រាយកំលាំងយោធាទេ ។



កំលាំងនៃកងឯកភាពការពារព្រំដែនរបស់កងទ័ពជើងគោក ធ្វើការល្បាតត្រួតពិនិត្យបង្គោលព្រំដែន ។

ត្រូវពិចារណាលើការបំពាក់ដោយសំភារៈ និងឧបករណ៍ចាំបាច់សមស្របមួយចំនួនដល់កំលាំងការពារព្រំដែន ដូចជាសំភារៈផ្ទាល់ខ្លួនសំរាប់ប្រតិបត្តិការតំបន់ព្រៃភ្នំ ហ្វីភីអេស វិទ្យុទាក់ទង មធ្យោបាយចល័តកំលាំង ស្បៀងអាហារ ជាដើម ។ ជំនាញបច្ចេកទេសផ្សេងៗទាក់ទងទៅនឹងការប្រឆាំងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងកាត់ព្រំដែន កំពុងត្រូវបានជួយផ្តល់ជាហូរហែដោយប្រទេសជាមិត្តមួយចំនួន ។

ដើម្បីធ្វើឱ្យកិច្ចការពារព្រំដែនមានប្រសិទ្ធិភាព និងជៀសវាងបាននូវភាពអសកម្ម ការបំពេញភារកិច្ចរបស់កំលាំងការពារព្រំដែនគ្រប់ប្រភេទត្រូវស្ថិតនៅក្រោម

ការសំរបសំរួល ។ នៅក្នុងការសំរបសំរួលផ្ទៃក្នុង គណៈបញ្ជាការឯកភាពខេត្ត ក្រុង អាច ជាយន្តការសំរបសំរួលមួយ សំរាប់កិច្ចសហប្រតិបត្តិការរវាងសមត្ថកិច្ចដែលពាក់ព័ន្ធ រីឯ គណៈកម្មាធិការរក្សាសន្តិភាពព្រំដែនតាមយោធភូមិភាគ មានតួនាទីសំរបសំរួលជាមួយ ដៃគូបរទេស ដូចដែលធ្លាប់ធ្វើមកជាប្រចាំ ។ ត្រូវធ្វើការកំណត់ឱ្យបានច្បាស់លាស់ផង ដែរ អំពីភារៈកិច្ចការពារព្រំដែន រវាងកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ។

ការរក្សាវត្តមានកំលាំងមនុស្សជាប្រចាំនៅតាមតំបន់ព្រំដែន គឺជាការចាំបាច់ ។ ដូច្នេះកំលាំងមនុស្សអាចរស់នៅបានអាស្រ័យផ្លូវគមនាគមន៍ ទឹក ភ្លើង និងការកសាងភូមិ ដ្ឋាន ។ កងវិស្វកម្មរបស់កងយោធពលខេមរភូមិន្ទ មានសមត្ថភាព និងធនធានមួយចំនួន អាចបំពេញភារកិច្ចកសាងផ្លូវគមនាគមន៍ស្របតាមបណ្តោយព្រំដែន បន្តិចម្តង១តទៅថ្ងៃ អនាគត ។ វារីអគ្គីសនីខ្នាតតូច អាចនឹងកសាងបាននៅតាមតំបន់ខ្លះ ទៅតាមអំណោយ ផលផ្ទៃកប្រភពទឹក ។ ក្រៅពីការរស់នៅរបស់ប្រជាពលរដ្ឋបន្ទាប់ពី មានហេដ្ឋារចនា សម្ព័ន្ធរួចហើយ យោធិនរំសាយដែលមានបំណងកសាងជីវភាពរស់នៅថ្មី ក៏អាចមកតាំង ទីលំនៅបានផងដែរ ។ម្យ៉ាងទៀតយោធិនរំសាយនេះ អាចនឹងក្លាយជាកំលាំងបំរុងសំរាប់ កាលៈទេសៈស្រុកទេសមានអាសន្ន ហើយសូមបញ្ជាក់ផងដែរថា ផ្លូវអភិវឌ្ឍន៍នេះគឺជា គមនាគមន៍យ៉ាងសំខាន់ សំរាប់បេសកកម្មការពារព្រំដែន ។

## សមត្ថភាពប្រឆាំងអំពើភេរវកម្ម:

ដូចដែលបានអធិប្បាយនៅក្នុងជំពូកខាងដើមរួចមកហើយ ការគំរាមកំហែងនៃ អំពើភេរវកម្ម គឺជាកង្វល់មួយដែលរាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ជានិច្ច ។ ថ្វី ត្បិតតែលទ្ធភាពនៃការវាយប្រហារដោយចំពោះមកលើប្រទេសកម្ពុជា អាចមានតិចតួច បំផុតក៏ដោយ វិធានការណ៍ជាក់ស្តែងមួយចំនួនត្រូវតែយកមកប្រើប្រាស់ ដើម្បីធានា ឱ្យបាននូវសន្តិសុខ និងសុវត្ថិភាពសំរាប់ប្រទេសជាតិ ។វិធានការណ៍ទាំងនោះរួមមាន:

- តាមឃ្លាំមើលយ៉ាងដិតដល់ ចំពោះចលនាជ្រុលនិយមណាមួយ នៅទូទាំងផ្ទៃ ប្រទេស ។

- ចំណាត់ការត្រួតពិនិត្យយ៉ាងហ្មត់ចត់ នៅតាមចំណុចឆ្លងកាត់ព្រំដែនទាំងអស់ ជាពិសេសច្រករបៀងដែនគោក ទន្លេ សមុទ្រ ដែលជាប់នឹងប្រទេសទាំងបី ។
- ពង្រឹងបន្ថែមទៀត នូវវិធានការគ្រប់គ្រងអាវុធជាតិផ្ទុះ ជាពិសេសត្រូវយកចិត្តទុកដាក់លើគ្រោះថ្នាក់ដ៏ធំធេង នៃការប្រើប្រាស់សារជាតិគីមីផ្សំធ្វើជាគ្រឿងផ្ទុះ ។
- ពង្រឹងវិធានការសន្តិសុខជាប្រចាំ នៅតាមគោលដៅទាំងឡាយ ដែលអាចទទួលរងការវាយប្រហារជាយថាហេតុ ដូចជាព្រលានយន្តហោះអន្តរជាតិ មណ្ឌលទេសចរណ៍ និងកន្លែងកំសាន្តសំខាន់ៗ គ្រឹះស្ថានសិក្សាខ្នាតអន្តរជាតិ ផ្សារទំនើប ស្ថានទូតបរទេស ជាដើម ។



ការហ្វឹកហាត់ជំនាញប្រឆាំងភេរវកម្ម របស់កងកំលាំងពិសេសនៃកងយោធពលខេមរភូមិន្ទ ។

- ព្យាយាមកាត់ផ្តាច់បណ្តាញភេរវកម្មពីខាងក្រៅ ជាពិសេសការលបជ្រៀតចូលរបស់បណ្តាញភេរវករ ការបញ្ចូលមនោគមវិជ្ជា ការផ្ទេរបច្ចេកវិជ្ជាតាមប្រព័ន្ធអ៊ិនធើណេត និងចរាចរផ្នែកហិរញ្ញវត្ថុរបស់ពួកភេរវករ ។
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ ដើម្បីស្វែងរកបន្ថែមទៀតនូវសមត្ថភាពផ្នែកបច្ចេកទេស ជំនាញ និងធនធាន និងពត៌មាន ។

លើសពីនេះទៅទៀត ប្រទេសកម្ពុជាកំពុងតែប្រកាន់យកនូវគោលជំហរយ៉ាងច្បាស់លាស់នៅក្នុងការប្រឆាំងអំពើភេរវកម្ម ដោយមានមាគ៌ានយោបាយ ៥ "ស" ជាគោលការណ៍:

**សុឆន្ទៈ:** រាជរដ្ឋាភិបាលបានបង្ហាញយ៉ាងច្បាស់អំពីសេចក្ដីប្ដេជ្ញាចិត្តរបស់ខ្លួននៅក្នុងការប្រយុទ្ធទល់នឹងអំពើភេរវកម្មអន្តរជាតិ ចាប់តាំងពីមានការវាយប្រហារថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០១ មក ។ ឥរិយាបទជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់អំពីកិច្ចសហប្រតិបត្តិការដោយសុទ្ធចិត្ត ជាមួយសហគមន៍អន្តរជាតិ ដោយមិនបណ្ដោយឱ្យឧក្រិដ្ឋជនប្រើប្រាស់ប្រទេសកម្ពុជាជាស្ថានសួគ៌សុវត្ថិភាពសំរាប់ពួកគេ និងសំរាប់បង្កមហន្តរាយផ្សេងៗ នោះឡើយ ។ កម្ពុជានឹងប្រកាន់យកនូវឥរិយាបទនេះជាបន្តទៀត ដើម្បីសេចក្ដីសុខក្សេមក្សាន្តរបស់ប្រទេសជាតិ ក៏ដូចជាសំរាប់ប្រជាជាតិនៅក្នុងតំបន់ និងនៅលើសាកលលោកទាំងមូល ។



*យុទ្ធជននៃកងពលតូចពិសេសឆ័ត្រយោងលេខ៩១១ កំពុងធ្វើការហ្វឹកហាត់យុទ្ធវិធីវាយរំដោះចំណាប់ខ្មាំង ដែលជាផ្នែកមួយនៃការហ្វឹកហ្វឺនជំនាញផ្នែកប្រឆាំងភេរវកម្ម ។*

**សមត្ថភាព:** កងយោធពលខេមរភូមិន្ទមានកងឯកភាពមួយចំនួន ដែលអាចបំពេញបេសកកម្មនៅក្នុងការប្រយុទ្ធទល់នឹងអំពើភេរវកម្មបាន ។ កងពលតូចឆ័ត្រយោង

លេខ៩១១ កងពលតូចលេខ៧០ កងរាជអាវុធហត្ថ កងឯកភាពស្ទួចរបស់កងទ័ពជើងទឹក គឺជាកំលាំងពិសេសដែលអាចយកមកប្រើប្រាស់បាននៅក្នុងការងារនេះ ។ តែទោះជាយ៉ាងណាក៏ដោយ សមត្ថភាពរបស់កងឯកភាពទាំងនេះនៅមានកំរិតនៅឡើយ ហើយទាមទារឱ្យមានទូវការហ្វឹកហ្វឺនជំនាញ និងការបំពាក់សំភារៈបន្ថែមទៀត ។



*កងទ័ពអាកាសភូមិន្ទកម្ពុជា រួមចំណែកយ៉ាងសំខាន់នៅក្នុងការហ្វឹកហ្វឺនកងឯកភាពប្រឆាំងភេរវកម្ម ។*

**សំរបសំរួល:** នៅក្នុងកាលៈទេសៈណាមួយដែលប្រទេសជាតិជួបប្រទះនឹងការវាយប្រហារពីសំណាក់ពួកភេរវករ កិច្ចសំរបសំរួលថ្នាក់ជាតិមួយត្រូវតែមានជាដាច់ខាត ដើម្បីត្រួតត្រាលើសភាពការណ៍ដែលកើតឡើង និងចាត់វិធានការណ៍តបតប្រកបដោយប្រសិទ្ធិភាព ។ យន្តការសំរបសំរួល ដែលមានគណៈកម្មាធិការជាតិដឹកនាំបញ្ជាការប្រយុទ្ធនិងទប់ស្កាត់អំពើភេរវកម្ម និងលេខាធិការដ្ឋានរបស់ស្ថាប័ននេះ មានតួនាទីសំខាន់ណាស់នៅក្នុងការសំរបសំរួលរវាងស្ថាប័ន ឬទីភ្នាក់ងារដែលពាក់ព័ន្ធទាំងអស់ ដូចជាកងយោធានគរបាល ទីភ្នាក់ងារស៊ើបការសំងាត់ សេវាផ្នែកពេទ្យ កិច្ចការបរទេស... ល នៅក្នុងការប្រើប្រាស់កំលាំង ការចាត់ចែងមធ្យោបាយ និងធនធាន និងការចាត់វិធានការណ៍ សម

ស្របទៅតាមសភាពការណ៍ ។ ស្ថាប័ន និងអង្គភាពដែលពាក់ព័ន្ធនីមួយៗ ក៏ត្រូវមាន យន្តការបែបនេះរបស់ខ្លួន សំរាប់បំរើឱ្យយន្តការថ្នាក់ជាតិ ។

**សហប្រតិបត្តិការ:** គ្មានប្រជាជាតិណាមួយ ឬក៏ស្ថាប័នណាមួយ អាចធ្វើការទប់ទល់នឹងអំពើភេរវកម្មដោយឯកឯងបានទេ ។ ការគំរាមកំហែងដ៏ធំធេងនេះទាមទារឱ្យមានការឆ្លើយតបពីសំណាក់ការរួមកិច្ចសហប្រតិបត្តិការជាឧបគោភាគី និងពហុភាគី ។ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងស្ថាប័នដែលពាក់ព័ន្ធដទៃទៀតក្តី កំពុងតែត្រូវការជាចាំបាច់ នូវការឧបត្ថម្ភគាំទ្រពីសំណាក់ដៃគូអន្តរជាតិ ដើម្បីពង្រីកសមត្ថភាពនៅក្នុងវិស័យនេះ ជាពិសេសធានាឱ្យបាននូវការត្រៀមលក្ខណៈគ្រប់ពេលវេលាដើម្បីឆ្លើយតបទៅនឹងសភាពការណ៍ និងសំភារៈឧបករណ៍សមស្របក្នុងការបំពេញភារកិច្ច ។

**សុនីតិ (ច្បាប់):** រាជរដ្ឋាភិបាលកម្ពុជាកំពុងបង្កើតឱ្យមានច្បាប់ប្រឆាំងអំពើភេរវកម្ម ដោយមានជំនួយគាំទ្រពីសំណាក់ប្រទេសអូស្ត្រាលី ។ ច្បាប់នេះនឹងបានជាមូលដ្ឋានក្នុងការអនុវត្តនីតិវិធានការណ៍ទាំងឡាយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

## សន្តិសុខដែនសមុទ្រ:

ព្រំដែនសមុទ្រនៃប្រទេសកម្ពុជា ជាតំបន់ដែលអាចទទួលរងការគំរាមកំហែងផ្នែកសន្តិសុខ រួមទាំងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនផងដែរ ។ វិបត្តមួយចំនួនដែលកើតមានឡើង ដូចជាបញ្ហាព្រំដែនទឹក ការលបលួចចូលនេសាទត្រីខុសច្បាប់ ការបាត់បង់ធនធានសមុទ្រ ...ល កំពុងស្ថិតនៅជាចំណោទមួយសំរាប់សន្តិសុខដែនសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជា ។

ដែនសមុទ្រនេះ គឺជាច្រកចូលសំរាប់បង្កើនពាណិជ្ជកម្មជាមួយប្រជាជាតិជុំវិញពិភពលោកផងដែរ ។ ឆ្នេរសមុទ្រ និងកោះទាំងឡាយ ជាគោលដៅទេសចរណ៍ដែលកំពុងមានការរីកចំរើន ហើយតំបន់នោះក៏ជាទីទាក់ទាញវិនិយោគបរទេសផងដែរ ។ ទ្រព្យ

សម្បត្តិដែនសមុទ្រទាំងនេះត្រូវតែការពារ ។ តែទោះជាយ៉ាងនោះក៏ដោយ ការទទួលខុសត្រូវ មិនមែនធ្លាក់មកលើកងទ័ពជើងទឹកតែឯងនោះទេ ។ ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធដទៃទៀត ក៏ត្រូវរួមចំណែកការទទួលខុសត្រូវចំពោះសន្តិសុខ និងការការពារដែនសមុទ្រផងដែរ ។ ហេតុដូច្នេះ វាជាការសំខាន់ណាស់ ក្នុងការបង្កើតឱ្យមានយន្តការសំរបសំរួលមួយ ដើម្បីកំណត់ឱ្យបានច្បាស់លាស់ ថាតើការទទួលខុសត្រូវទាំងនេះត្រូវចែករំលែកដោយរបៀបណា ។ កងទ័ពជើងទឹកគឺជាភ្នាក់ងាររាជរដ្ឋាភិបាលឈានមុខគេ នៅក្នុងកិច្ចប្រតិបត្តិការលើលំហសមុទ្រ ។ កងទ័ពជើងទឹកមានអាណត្តិរបស់ខ្លួនក្នុងឋានៈជាកងកំលាំងរបស់ប្រទេសជាតិ ដែលមានអំណាចត្រួតត្រានៅឯតំបន់សមុទ្រ ។ ដូច្នេះ កងទ័ពជើងទឹកមានតួនាទីមួយក្នុងការជួយដល់ស្ថាប័នរាជរដ្ឋាភិបាលផ្សេងៗទៀត ដើម្បីសំរេចបាននូវបេសកកម្មរបស់គេនៅទីនោះ ។



*ទស្សនកិច្ចរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ ( ឧ.ឧ. ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ ) នៃក្រសួងការពារជាតិភូមិន្ទ និងអនុព័ន្ធយោធានៃបណ្តាប្រទេសនានា ជាមួយនឹងយុទ្ធជននៃកងទ័ពជើងទឹកភូមិន្ទកម្ពុជា នៅលើកោះពូលូវ៉ៃ ក្នុងដែនសមុទ្រកម្ពុជា ។*

តំបន់សេដ្ឋកិច្ចផ្តាច់មុខនៃដែនសមុទ្រ គឺជាប្រភពសេដ្ឋកិច្ចយ៉ាងសំខាន់របស់ប្រទេសជាតិ ។ ប្រទេសកម្ពុជាមានសិទ្ធិអំណាចក្នុងការត្រួតត្រាលើការរុករក ការធ្វើ

អាជីវកម្ម និងការថែរក្សាគ្រប់គ្រងធនធានធម្មជាតិសរីរាង្គ ឬអសរីរាង្គ នៃបាតសមុទ្រ ស្រទាប់ដីក្រោមសមុទ្រ និងដែនទឹកនៅផ្នែកខាងលើ ព្រមទាំងសកម្មភាពផ្សេងទៀត ដែលនាំទៅរកការរុករក និងការធ្វើអាជីវកម្ម ។



ការហ្វឹកហ្វឺនជំនាញមុជទឹករបស់កងកំលាំងពិសេសនៃកងពលតូចឆ័ត្រយោងពិសេសលេខ៩១១ ។

បរិដ្ឋានដែនសមុទ្រមានសក្តានុពលយ៉ាងធំធេង ជាច្រកចូល និងជាផ្លូវពាណិជ្ជកម្មជាអាយុជីវិតមួយ ប៉ុន្តែវាក៏ងាយរងគ្រោះ និងពិបាកក្នុងការគ្រប់គ្រងផងដែរ ។ ដើម្បីសំរេចឱ្យបាននូវគោលដៅរបស់ជាតិ វាជាការចាំបាច់ត្រូវ:

- ថែរក្សាបូរណភាពដែនទឹក និងការការពារធនធាននៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់កម្ពុជា ដែលនឹងធានាថា ភោគទ្រព្យដែនសមុទ្រអាចត្រូវបានប្រើប្រាស់សំរាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព ។
- ថែរក្សាសន្តិភាព និងកិច្ចសហប្រតិបត្តិការ នៅក្នុងតំបន់ដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសជិតខាង ។

- ការពារផ្លូវពាណិជ្ជកម្មដែនសមុទ្រ និងការដឹកជញ្ជូនតាមកបាល់ ដើម្បីធ្វើឱ្យប្រាកដថា តមនាគមន៍ជាអាយុជីវិតទាំងនេះ ត្រូវបានធានា សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការដោះដូរសេដ្ឋកិច្ចជាមួយដៃគូពាណិជ្ជកម្មរបស់កម្ពុជា ។
- ផ្តល់ការទប់ស្កាត់ រាល់សកម្មភាពល្មើសច្បាប់ដែលកើតមាននៅក្នុងបរិស្ថានដែនសមុទ្រ និងរួមវិភាគទានដល់ការរក្សាសន្តិសុខដែនសមុទ្រនៅក្នុងតំបន់ ។ ទាំងនោះរួមមាន ការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ចោរសមុទ្រ និងការរត់ពន្ធ ការដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់ អាវុធ មនុស្ស និងការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ។
- មានលទ្ធភាពអាចឆ្លើយតបចំពោះគ្រោះមហន្តរាយផ្សេងៗ ទាំងគ្រោះធម្មជាតិដោយបច្ចេកទេស និងគ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស សំរាប់សុវត្ថិភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការការពារទ្រព្យសម្បត្តិដែនសមុទ្រ ។

ដើម្បីសំរេចឱ្យបាននូវគោលដៅទាំងនេះ កងទ័ពជើងទឹកត្រូវបង្កើនសមត្ថភាពដែនសមុទ្ររបស់ខ្លួន ដែលមានលទ្ធភាពអាចៈ

ក. បញ្ជេញកំលាំងយោធានៅឯសមុទ្របាន

ខ. ធ្វើការល្បបយកការណ៍ និងប្រតិបត្តិការល្បាតបាន

គ. មានសមត្ថភាពក្នុងការហាមឃាត់នាវា និងឡើងលើនាវាបាន

ឃ. មានសមត្ថភាពក្នុងប្រតិបត្តិការរុករក និងសង្គ្រោះ

ង. ដឹកជញ្ជូន និងគាំទ្រដល់កំលាំងប្រដាប់អាវុធ និងអាជ្ញាធររដ្ឋបាលស៊ីវិល

ច. ធ្វើប្រតិបត្តិការមុជទឹក និងការកំទេចយុទ្ធភ័ណ្ឌ

ឆ. ហ្វឹកហ្វឺន និងប្រតិបត្តិការជាមួយកំលាំងប្រដាប់អាវុធនៅក្នុងតំបន់

សមត្ថភាពជាមូលដ្ឋានដែល ធ្វើឱ្យកងទ័ពជើងទឹកអាចបំពេញភារកិច្ចរបស់ខ្លួនបាន គឺការល្បាតជាប្រចាំនៅក្នុងដែនទឹក និងតាមបណ្តាកោះ ។ សមត្ថភាពជាមូលដ្ឋាននេះ ទាមទារឱ្យមានការនាំយកនាវាល្បាតមួយចំនួន មកជួសជុល ហើយដាក់ឱ្យប្រើការ

ព្រមទាំងមធ្យោបាយចាំបាច់ដូចជាប្រេងឥន្ធនៈសំរាប់ធ្វើកិច្ចប្រតិបត្តិការ ។ កងទ័ពជើងទឹកកម្ពុជាត្រូវការនូវបច្ចេកទេស និងជំនាញមួយចំនួន សំរាប់ធ្វើកិច្ចប្រតិបត្តិការប្រឆាំងទល់នឹងឧក្រិដ្ឋកម្មឆ្លងដែន និងការជ្រៀតចូលនៃអំពើភេរវកម្ម ហើយបច្ចេកទេស និងជំនាញទាំងនេះកំពុងត្រូវបានអភិវឌ្ឍជាបណ្តើរៗ ដោយមានការឧបត្ថម្ភគាំទ្រពីសំណាក់ដៃគូសន្តិសុខអន្តរជាតិ ។ ការប្រើប្រាស់យន្តហោះនៅក្នុងការឃ្លាំមើលដែនសមុទ្រ គឺជាជំនួយដ៏មានប្រសិទ្ធិភាពមួយ បើសិនណាជាអាចធ្វើទៅបាន ។ យន្តហោះដែលមានបំពាក់ឧបករណ៍ឃ្លាំមើល អាចធ្វើប្រតិបត្តិការនៅលើផ្ទៃទឹកធំធេងបានក្នុងរយៈពេលខ្លី និងអាចធ្វើដំណើរទៅដល់គោលដៅបានឆាប់រហ័ស ។



*មេបញ្ជាការកងទ័ពជើងទឹកភូមិន្ទកម្ពុជាថ្លែងសុន្ទរកថា នៅក្នុងពិធីប្រគល់នាវាល្បាត ២គ្រឿង ដែលជាអំណោយរបស់កងទ័ពជើងទឹកវៀតណាម ជូនកងទ័ពជើងទឹកភូមិន្ទកម្ពុជា កាលពីខែកុម្ភៈ ឆ្នាំ២០០៦ នៅមូលដ្ឋានកងទ័ពជើងទឹក រាម ។*

នៅក្នុងអនាគតដ៏ខ្លីនេះ កងទ័ពជើងទឹកនឹងបានទទួលនូវសំភារៈថ្មីមួយចំនួន រួមទាំងនាវាល្បាត នាវាប្រដេញ ឧបករណ៍រ៉ាដា និងរោងជាងជួសជុល ផងដែរ ។ សំភារៈទាំងនេះនឹងជួយបង្កើនប្រសិទ្ធិភាពនៃការធានាសន្តិសុខដែនសមុទ្រ ។ តែទោះជាយ៉ាង

ណាក៏ដោយ ស្ថាប័នដែលពាក់ព័ន្ធត្រូវតែគិតគូរពិចារណាដោយយកចិត្តទុកដាក់ ទៅលើនិរន្តរភាពនៃកិច្ចប្រតិបត្តិការរបស់សំភារៈទាំងនោះ ការថែទាំ និងវិធានការចាំបាច់ សំរាប់សំរបសំរួលកិច្ចប្រតិបត្តិការរបស់កងទ័ពជើងទឹក ជាមួយនឹងសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត នៅក្នុងតំបន់ដែលខ្លួនទទួលខុសត្រូវ ។

ការធ្វើល្បាតរួមគ្នាលើផ្ទៃសមុទ្រជាមួយប្រទេសជិតខាង គឺជាមធ្យោបាយមួយដ៏ល្អដើម្បីកាត់បន្ថយវិបត្តព្រំដែន សកម្មភាពល្មើសច្បាប់ផ្សេងៗ សកម្មភាពចោរសមុទ្រ ការជ្រៀតចូលនៃអំពើភេរវកម្ម បញ្ហាឧក្រិដ្ឋកម្មឆ្លងដែន... ។ល។ តាមកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាជាមួយប្រទេសវៀតណាម កងទ័ពជើងទឹកកម្ពុជានឹងត្រូវធ្វើល្បាតរួមគ្នាជាមួយកងទ័ពជើងទឹកវៀតណាម ។ សកម្មភាពបែបនេះនឹងត្រូវធ្វើជាមួយប្រទេសថៃទៀត ស្របតាមការស្នើសុំរបស់ភាគីថៃ ដែលមានតាំងពីឆ្នាំ១៩៩៩មកម្លេះ ។

## សមត្ថភាពប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន:

ឧក្រិដ្ឋកម្មឆ្លងដែនគឺជាការគំរាមកំហែងជាប្រចាំ មកលើសន្តិសុខសង្គមនៃប្រទេសកម្ពុជា ។ សកម្មភាពល្មើសច្បាប់ទាំងនោះមានរួមបញ្ចូលចរាចរគ្រឿងញៀន អំពើជួញដូរមនុស្ស ការរត់ពន្ធគ្រប់ប្រភេទ ការលាងលុយកខ្វក់ និងការជួញដូរបិតិកភ័ណ្ឌជាតិ ជាដើម ។ នៅក្នុងរយៈកន្លងមកនេះ កងយោធពលខេមរភូមិន្ទបានរួមចំណែកយ៉ាងសកម្ម នៅក្នុងវិធានការទប់ស្កាត់ និងបង្ក្រាប ដោយរួមកិច្ចសហប្រតិបត្តិការជាមួយសមត្ថកិច្ចពាក់ព័ន្ធមួយចំនួន ។ តែទោះជាដូច្នេះក្តី កងយោធពលខេមរភូមិន្ទត្រូវការនូវសមត្ថភាពជំនាញបន្ថែមទៀត ដើម្បីធ្វើឱ្យចំណាត់ទាំងឡាយ ត្រូវបានអនុវត្តន៍ទាន់ពេលវេលា និងមានប្រសិទ្ធិភាព ។

ជាការពិតណាស់ ដើម្បីស្តារសភាពការណ៍ឱ្យទាន់ពេលវេលា អាជ្ញាធរមានសមត្ថកិច្ចដែលជាប់ពាក់ព័ន្ធទាំងអស់ ត្រូវបង្កើនការយល់ដឹងអំពីគ្រោះថ្នាក់ដែលមានកំរិតកាន់តែធ្ងន់ធ្ងរឡើងៗចំពោះសង្គមខ្មែរ ហើយផ្តោតការយកចិត្តទុកដាក់ទ្វេឡើងទៀត ទៅ

លើការជំរុញឱ្យវិធានការទាំងឡាយដែលកំពុងប្រើប្រាស់ ប្រកបដោយប្រសិទ្ធិភាពយ៉ាងពិតប្រាកដ ។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជាម្នាក់ឯងពុំអាចទប់ទល់នឹងការគំរាមកំហែងដ៏ធំធេងនេះបានទេ ។ កិច្ចសហការពីខាងក្រៅគឺជាតំរូវការចាំបាច់ ដើម្បីកសាងសមត្ថភាពអាជ្ញាធរអនុវត្តន៍ច្បាប់កម្ពុជា ឱ្យឆ្លើយតបប្រកបដោយប្រសិទ្ធិភាពទៅនឹងគ្រោះមហន្តរាយនេះ ។ បច្ចុប្បន្ននេះ រដ្ឋាភិបាលសហរដ្ឋអាមេរិកកំពុងយកចិត្តទុកដាក់ក្នុងការផ្តល់ការហ្វឹកហ្វឺនដល់កងយោធា និងនគរបាលខ្មែរ ព្រមទាំងស្ថាប័នអនុវត្តន៍ច្បាប់ផ្សេងទៀត អំពីសមត្ថភាពមួយចំនួន ដែលអាចនាំឆ្ពោះទៅរកលទ្ធភាពនៃការបំពេញកិច្ចប្រតិបត្តិការរួមគ្នា នៅតាមចំណុច និងច្រកយុទ្ធសាស្ត្រមួយចំនួន ដូចជាច្រកប៉ោយប៉ែតច្រកកោះកុង រាម និងច្រកទន្លេមេគង្គព្រំដែនភាគខាងជើង ។



រ.៩. ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលបន្សាបសារធាតុញៀនរបស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ។

វិធានការសំខាន់ និងកំពុងតែទទួលលទ្ធផលជាផ្លែផ្កាមួយទៀត គឺការប្រមូលជនដែលរងគ្រោះដោយការសេពថ្នាំញៀន មកទទួលការអប់រំបន្សាបការញៀន ដែលកំពុងអនុវត្តន៍ដោយកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង ។ ការបង្កើតឱ្យ

មានកម្មវិធីដូចនេះនៅតាមទីកន្លែងដ៏ទៃទៀតគឺជាការប្រពៃ ដោយហេតុថា វិធានការនេះកំពុងតែមានដំណើរល្អ និងមានការគាំទ្រពីសំណាក់មជ្ឈដ្ឋានជាច្រើននៅក្នុងសង្គមជាតិ ។



កងរាជអាវុធហត្ថចូលរួមយ៉ាងសកម្មនៅក្នុងការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ។ រូបនេះបង្ហាញពីសកម្មភាពកាប់ផ្ដាច់ដើមកញ្ឆា ។

ការទប់ស្កាត់ និងបង្ក្រាបបទល្មើសផ្សេងៗទៀត តំរូវឱ្យមានកិច្ចសហការជិតស្និតថែមទៀតរវាងអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធទាំងឡាយ ជាពិសេសការចូលរួមឱ្យបានពេញទំហឹងពីសំណាក់កងរាជអាវុធហត្ថ ។ នៅក្នុងភារកិច្ចដ៏ស្មុគ្រស្មាញនេះ ការធ្វើឱ្យកងរាជអាវុធហត្ថមានតួនាទីពេញលេញ នៅក្នុងការអនុវត្តន៍ភារកិច្ចនគរបាលយុត្តិធម៌ឡើងវិញ គឺជាការចាំបាច់ និងធ្វើឱ្យបានឆាប់ ជាពិសេសការកំណត់ភារៈកិច្ចនេះនៅក្នុងក្រមនីតិវិធីព្រហ្មទ័ណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ។

នៅក្នុងពិធីដុតបំផ្លាញអាវុធ ដើម្បីបញ្ចប់កិច្ចសហប្រតិបត្តិការរវាងគណៈកម្មការជាតិកែទំរង់ការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ជាមួយសហភាពអឺរ៉ុប នៅខេត្តកណ្តាល កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានប្រកាសដាក់បទបញ្ជា ៨ចំណុច ទាក់ទិនទៅនឹងវិធានការពង្រឹងសន្តិសុខ និងសណ្តាប់

ធ្លាប់សង្គម ។ កងយោធពលខេមរភូមិន្ទ មានកាតព្វកិច្ចរួមចំណែកក្នុងការអនុវត្តន៍បទបញ្ជាទាំង ៨ចំណុចដូចខាងក្រោមនេះ ឱ្យបានសំរេចជោគជ័យជាស្ថាពរ:

***ទី១.*** ត្រូវបន្តលើកកំពស់ស្មារតីទទួលខុសត្រូវ ក្នុងការពង្រឹងសន្តិភាព ស្ថិរភាព ការពង្រឹងនីតិរដ្ឋ សណ្ដាប់ធ្នាប់សង្គម ដើម្បីបង្កបុព្វបទសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ ។

***ទី២.*** បន្តបង្កើនប្រសិទ្ធភាពការងារ ដើម្បីទប់ស្កាត់បទល្មើសគ្រប់ប្រភេទ ពិសេសការបំបាត់អំពើឃាតកម្ម ប្លន់ប្រដាប់អាវុធ អំពើចាប់ជំរិត ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការជួញដូរស្ត្រី កុមារ ព្រមទាំងសកម្មភាពល្មើសច្បាប់ផ្សេងៗទៀត ដែលបង្កឱ្យមានការភ័យខ្លាចក្នុងសង្គម ។



*សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងតំណាងកម្មវិធី EU-ASAC កំពុងបញ្ឆេះភ្លើងដុតកំទេចអាវុធដែលរកឃើញក្រោយនៃកិច្ចសហប្រតិបត្តិការជាមួយកម្មវិធី EU-ASAC (អណ្ដាតភ្លើងសន្តិភាព) នៅក្រុងតាខ្មៅ កាលពីខែមិថុនា ឆ្នាំ២០០៦ ។*

***ទី៣.*** បន្តកិច្ចសហការជាមួយសហគមន៍ជាតិ និងអន្តរជាតិ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់ និងប្រឆាំងរាល់សកម្មភាពភេរវកម្ម វិទ្ធង្សនាតាមគ្រប់រូបភាព ទាំងក្នុង និងក្រៅប្រទេស ។

***ទី៤.*** ត្រូវអនុវត្តដោយម៉ឺងម៉ាត់នូវច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០០៥ កន្លងទៅនេះ ។

***ទី៥.*** ពង្រឹងការគ្រប់គ្រងអាវុធគ្រាប់រំសេវនៅគ្រប់កងឯកភាព ជាពិសេសត្រូវកាត់បន្ថយការប្រើប្រាស់អាវុធក្នុងករណីដែលមិនចាំបាច់ ហើយត្រូវរក្សាទុកដាក់អាវុធនៅទីកន្លែងដែលមានសុវត្ថិភាពបំផុត ។ រាល់បទល្មើសពាក់ព័ន្ធនឹងការប្រើប្រាស់អាវុធត្រូវអនុវត្តតាមច្បាប់របស់រដ្ឋ ឱ្យបានតឹងរ៉ឹងបំផុត ។

***ទី៦.*** បន្តស្រាវជ្រាវរុករក និងប្រមូលដកហូតអាវុធជាតិផ្ទុះគ្រប់ប្រភេទ ដែលនៅសេសសល់ពីសម័យសង្គ្រាម រួមទាំងអាវុធដែលជនខិលខូចលួចលាក់ប្រើប្រាស់ខុសច្បាប់ ដើម្បីយកមកបំផ្លាញចោលឱ្យអស់ ។ ព្រមជាមួយនោះ ក៏ត្រូវបង្កើនការត្រួតពិនិត្យទប់ស្កាត់ និងបង្ក្រាបទាន់ពេល ចំពោះការចរាចរអាវុធជាតិផ្ទុះដោយខុសច្បាប់ពីតំបន់មួយទៅតំបន់មួយទៀត ។

***ទី៧.*** សូមបងប្អូនជនរួមជាតិទាំងអស់យល់ថា អាវុធគឺជាឧបករណ៍ និងជាប្រភពដ៏ចម្បង ក្នុងការជំរុញឱ្យមានអំពើហិង្សា ឧក្រិដ្ឋកម្ម ដែលជះឥទ្ធិពលដល់សន្តិសុខ សុវត្ថិភាពសង្គម ជាពិសេសការរស់នៅប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ ដូច្នេះការប្រគល់អាវុធ ឬការចង្អុលបង្ហាញកន្លែងលាក់អាវុធដល់អាជ្ញាធរមានសមត្ថកិច្ច គឺជាការរួមចំណែកការពារសេចក្តីសុខ សន្តិភាព និងសុវត្ថិភាព សម្រាប់ខ្លួនយើង ក្រុមគ្រួសារយើង សហគមន៍ និងសម្រាប់សង្គមជាតិទាំងមូល ។

***ទី៨.*** ចំពោះមន្ត្រីរាជការ នាយទាហាន នាយនគរបាល នាយកងរាជអាវុធហត្ថ ដែលអនុក្រឹត្យថ្មីបានអនុញ្ញាតឱ្យមានអាវុធខ្លីសម្រាប់ការពារខ្លួន ត្រូវរក្សាអាវុធនេះឱ្យបានល្អ ចៀសវាងបណ្តែតបណ្តោយឱ្យកូន ក្មួយ បងប្អូន ញាតិមិត្ត ប្រើប្រាស់អាវុធនេះ ទោះក្នុងគោលដៅអ្វីក៏ដោយ ។

## អព្យាក្រឹតផ្នែកនយោបាយរបស់កងយោធពលខេមរភូមិន្ទ:

យោធិនគ្រប់រូបត្រូវឱ្យមានឆន្ទៈ និងការលះបង់ខ្ពស់នៅក្នុងកិច្ចការពារ និងកសាងជាតិមាតុភូមិ ។ ឆន្ទៈនេះអាចនឹងដុះដាលឡើងបាន លុះត្រាណាតែផលប្រយោជន៍ជាតិត្រូវបានគេយកមកដឹកល់នៅក្នុងឧត្តមគតិរបស់យោធិនទាំងនោះ ។ ការធ្វើឱ្យមានអព្យាក្រឹតភាពនៅក្នុងជួរកងទ័ព ស្ថិតនៅជាអាទិភាពនៅក្នុងដំណើរការកែទំរង់កងយោធពលខេមរភូមិន្ទ ហើយវិធានការមួយចំនួនអាចនឹងជួយជំរុញឱ្យដំណើរការនេះទទួលបានលទ្ធផលល្អប្រសើរ ។

- ស្របពេលដែលមានការកាត់រំសាយកងទ័ពជាបន្តទៅទៀត ការជ្រើសរើសយោធិនថ្មីតាមច្បាប់ត្រឹមត្រូវ អាចបង្កើនកំលាំងថ្មីនៅក្នុងជួរកងយោធពលខេមរភូមិន្ទតទៅថ្ងៃអនាគត អនុលោមទៅតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅរបស់កងយោធពលខេមរភូមិន្ទ ។ វិធានការនេះត្រូវធ្វើតាមរយៈប្រព័ន្ធយោធិនបំរុង ឬច្បាប់កាតព្វកិច្ចយោធា ។
- យោធិនទាំងឡាយ មិនថាស្ថិតនៅក្នុងលំដាប់ណា ត្រូវតែដាក់ឱ្យចូលនិវត្តន៍តាមពេលកំណត់ ឬត្រូវបានដាក់បញ្ចូលក្នុងគំរោងកាត់រំសាយ ឬដាក់ឱ្យចូលនិវត្តន៍មុនពេលកំណត់បើជាការចាំបាច់ ។
- ការអប់រំរៀនសូត្រ ត្រូវប្រមូលផ្តុំលើការខិតខំធ្វើឱ្យយោធិនមានចំណេះដឹងផ្នែកយោធាបានបរិបូរ និងប្រែក្លាយជាយោធិនអាជីព ។ ការបណ្តុះបណ្តាលឧត្តមគតិស្នេហាជាតិ សាសនា ព្រះមហាក្សត្រ ព្រមទាំងសេចក្តីស្មោះត្រង់នឹងរាជរដ្ឋាភិបាល និងតំលៃនៃលទ្ធិប្រជាធិបតេយ្យ គឺជាការចាំបាច់បំផុត ។

### ការកាត់បន្ថយកំលាំងទ័ព:

នៅក្នុងសៀវភៅ ស ការពារជាតិ ឆ្នាំ២០០០ រាជរដ្ឋាភិបាលបានកំណត់ឱ្យមានការកាត់បន្ថយចំនួនបុគ្គលិកយោធា ៥៥.០០០នាក់ ចាប់តាំងពីឆ្នាំ១៩៩៩មក ។ វិធានការនេះ ត្រូវបានអនុវត្តន៍បណ្តើរៗ ហើយក៏ជួបប្រទះនឹងភាពរអាក់រអួលនៅក្នុងឆ្នាំ២០០២ ជាមួយនឹងការសេសសល់យោធិនចំនួន ១៥.០០០នាក់ទៀត ពុំទាន់បានកាត់រំសាយ ។ ទាំងសៀវភៅ ស ការពារជាតិ ឆ្នាំ២០០០ ទាំងឯកសារិវេចនាលើយុទ្ធសាស្ត្រការពារជាតិ ឆ្នាំ២០០២ ក៏ដូចជាកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៣នេះ សុទ្ធតែសង្កត់ធ្ងន់ទៅលើការចង់បាននូវកងយោធពលមួយដែលមានទំហំសមស្រប និងប្រកបដោយគុណភាព ។ បើយើងពិនិត្យឱ្យបានដិតដល់អំពីសភាពការសន្តិសុខទូទៅ និងតំរូវការសំរាប់កិច្ចការពារជាតិ ទាំងនៅពេលនេះ និងនៅពេលអនាគត ឃើញថាព្រះរាជាណាចក្រកម្ពុជាអាចធ្វើការកាត់បន្ថយទំហំកងយោធាបានតាមវិធានការដូចខាងក្រោម:

- ការកាត់បន្ថយទំហំកងទ័ពនៅក្នុងរយ:ពេល៥ឆ្នាំខាងមុខ ពាក់ព័ន្ធមួយភាគធំទៅនឹងការបញ្ចេញយោធិនប្រភេទពីរ ។ ផ្អែកតាមនីតិវិធីរបស់រដ្ឋ និងនយោបាយស្តីពីការកែទំរង់កងកំលាំងប្រដាប់អាវុធ រាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវលៃលក និងបង្កលក្ខណ:ឱ្យការបញ្ចេញយោធិនប្រភេទនេះប្រព្រឹត្តទៅបានឆាប់ ពុំនោះសោតទេ បញ្ហានេះនឹងធ្វើអោយប៉ះពាល់ដល់ការរៀបចំរចនាសម្ព័ន្ធថ្មី ការអភិវឌ្ឍន៍ធនធានមនុស្ស ហើយជាពិសេសទៅទៀតនោះ គឺប៉ះពាល់ដល់ការអនុវត្តន៍ច្បាប់ស្តីពីកាតព្វកិច្ចយោធា ។
- កំណត់ឱ្យច្បាស់លាស់អំពីចំនួនកងទ័ពទាំងមូលដែលត្រូវរក្សាទុក ជាជាងកំណត់ចំនួនដែលត្រូវកាត់បន្ថយ ។ ដើម្បីឱ្យមានតុល្យភាពនៅក្នុងការប្រើប្រាស់ថវិការដ្ឋ ស្ថានភាពសេដ្ឋកិច្ច និងយោលទៅលើតំរូវការជាក់ស្តែងសំរាប់កិច្ចការពារជាតិមាតុភូមិ កងយោធពលខេមរភូមិន្ទត្រូវបន្ថយចំនួនបុគ្គលិកយោធាពី២៥ ទៅ៣០ភាគរយទៀត រហូតដល់ឆ្នាំ២០១០ ។

- ការបញ្ចេញយោធិនពីជួរកងទ័ព ត្រូវធ្វើនៅគ្រប់លំដាប់ថ្នាក់ ទោះជាថ្នាក់ឧត្តមសេនិយក៏ដោយ ។ លើសពីនេះទៅទៀត ត្រូវជៀសវាងរើសអើង និងការប្រកាន់អតីតភាព ។



ថ្នាក់ដឹកនាំក្រសួងការពារជាតិ និងអគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ នៅក្នុងពិធីបើកសិក្ខាសាលាបូកសរុបលទ្ធផលការងាររបស់កងយោធពលខេមរភូមិន្ទរយៈពេល ៥ឆ្នាំ (២០០០-២០០៤) និងទិសដៅបន្ត (២០០៥-២០០៨)

- យោធិននីមួយៗត្រូវទទួលបានការហ្វឹកហ្វឺនវិជ្ជាជីវៈ បើសិនជាគេត្រូវការ ឬការឧបត្ថម្ភណាមួយ យោលទៅលើស្ថានភាពជីវភាពជាក់ស្តែង នៅមុនពេលកាត់រំសាយ ។ ការអប់រំហ្វឹកហ្វឺនវិជ្ជាជីវៈសំរាប់យោធិនដែលត្រូវចេញពីជួរកងទ័ព ផ្តល់នូវចំណេះដឹងជាមូលដ្ឋាន សំរាប់ជាទុនក្នុងការប្រកបមុខរបរខ្នាតតូច ព្រមទាំងជួយជំរុញឱ្យមានការស្ម័គ្រចិត្តចូលនិវត្តន៍មុនពេលកំណត់ ។
- ការចូលនិវត្តន៍ត្រូវតែអនុវត្តតាមច្បាប់ដែលមានជាធរមានរួចហើយ ។ ធ្វើការលើកទឹកចិត្តឱ្យមានការចូលនិវត្តន៍មុនពេលកំណត់ ។
- ត្រូវមានការត្រួតពិនិត្យឱ្យបានហ្មត់ចត់ថែមទៀត ឬធ្វើការកាត់បន្ថយឱ្យបានជាអតិបរមាបើចាំបាច់ នូវការតំលើងឋានន្តរស័ក្តនាយទាហានថ្នាក់

ឧត្តមសេនីយ និងនាយទាហានជាន់ខ្ពស់ដ៏ទៃទៀត ដើម្បីរក្សាតុល្យភាពរវាងនាយទាហាន និងពលទាហាន ។ វិធីសាស្ត្រមួយចំនួនអាចត្រូវយកមកប្រើ ដូចជាការចូលនិវត្តន៍ បញ្ឈប់ការតំលើងឋានន្តរសក្តិតាមមុខតំណែង បង្កើតឱ្យមានឋានន្តរសក្តិបណ្តោះអាសន្នឬកិត្តិយសសំរាប់ពេលមានតំនៀបសង្កត់ផ្នែកនយោបាយ ផ្លាស់ប្តូរការងារនាយទាហានឱ្យបានញឹកញាប់ដើម្បីបង្កើនបទពិសោធន៍ និងតំលើងឋានន្តរសក្តិឱ្យត្រឹមត្រូវទៅតាមក្រឹត្យក្រម និងពេលវេលា ។ បើមានការចាំបាច់ ត្រូវធ្វើវិសោធនកម្មលើច្បាប់លក្ខន្តិកៈទូទៅរបស់កងយោធពលខេមរភូមិន្ទ ត្រង់ចំណុចការតំលើងឋានន្តរសក្តិនាយទាហានថ្នាក់ឧត្តមសេនីយ៍ ដោយឱ្យមានការកំណត់ពេលវេលាច្បាស់លាស់ ។

- កងយោធពលខេមរភូមិន្ទត្រូវគិតគូរឡើងវិញអំពីភាពស្មើគ្នានៃយេនឌ័រ ។ *គោលការណ៍សំខាន់គឺផ្តល់តំលៃស្មើគ្នាទៅនឹងបុរស សំរាប់ស្ត្រីនៅក្នុងជួរកងទ័ព* នៅក្នុងការជ្រើសរើស ការបំពេញការងារ ការតំឡើងឋានៈ និងការទទួលផលប្រយោជន៍ ។
- នៅពេលដែលដំណើរការកាត់បន្ថយជឿនលឿនទៅមុខ ឆ្ពោះទៅរកគោលដៅនៃទំហំកងទ័ពដែលត្រូវរក្សាទុក កងយោធពលខេមរភូមិន្ទត្រូវការបញ្ចូលកំលាំងថ្មីមកវិញ ១០ភាគរយ (រហូតដល់ឆ្នាំ២០១០) ដែលនឹងត្រូវអនុវត្តនៅក្រោមច្បាប់កាតព្វកិច្ចយោធា ឬប្រព័ន្ធយោធាបំរុង ។

## ការតសាងកំលាំងទ័ព:

កងឯកភាព និងទីតាំងរបស់កងយោធពលខេមរភូមិន្ទក្នុងពេលបច្ចុប្បន្ន ត្រូវតែមានការកែសំរួលជាបន្តទៅទៀត ។ អនុលោមតាមគោលការណ៍កាត់បន្ថយទំហំទ័ពខាងដើម ចំនួនកងឯកភាពគ្រប់ប្រភេទត្រូវតែមានការថយចុះ ។ តែទោះជាដូច្នេះក្តី ការរក្សាខ្នាតកងឯកភាពខ្ពស់បំផុតត្រឹមថ្នាក់កងពលតូច គឺសមរម្យណាស់ នេះគឺយើងគិតអំពីការ

បំពាក់គ្រឿងយុទ្ធោបករណ៍ ការចល័តកំលាំង ការគ្រប់គ្រង និងការដឹកនាំបញ្ជាទ័ព ។ នៅក្នុងចំនួនទ័ពសរុប ដែលនឹងត្រូវកាត់បន្ថយជាបន្តបន្ទាប់នោះ ៨០ភាគរយឬស្មើនឹង ៤ភាគ៥ គឺជាកំលាំងប្រតិបត្តិការ រីឯ ២០ភាគរយឬសំណល់ ១ភាគ៥ គឺជាកំលាំងដឹកនាំបញ្ជានៅទីបញ្ជាការកណ្តាល និងនៅតាមបណ្តាយោធភូមិភាគ ព្រមទាំងកំលាំងឯកទេសមួយចំនួន ។ នៅក្នុងការរៀបចំកំលាំងយោធានៅតាមប្រភេទទ័ពនីមួយៗ (ជើងគោក ជើងទឹក ជើងអាកាស) ត្រូវពិចារណាលើទ្រង់ទ្រាយសមស្របមួយ គឺ ១០ភាគរយជាកំលាំងដឹកនាំបញ្ជា ៥០ភាគរយ ជាកំលាំងប្រយុទ្ធ (ថ្មើជើង រថក្រោះ...ល) ២០ភាគរយជាកំលាំងគាំទ្រ (កាំភ្លើងធំ ការពារអាកាស ទ័ពជាង...ល) និង ២០ភាគរយជាកំលាំងចលនូបត្ថម្ភ ។ ត្រូវរក្សាកងឯកភាពអន្តរាគមន៍មួយចំនួនជាជរាប ។



*ឯកឧត្តម នាយឧត្តមសេនីយ មាស សុភា អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោកភូមិន្ទកម្ពុជា កំពុងត្រួតពលនៃកងឯកភាពរថក្រោះ ។*

នៅពេលដែលការកាត់បន្ថយចំនួនបុគ្គលិកយោធា បានដល់ចំនួនដែលត្រូវរក្សាទុក និងនៅពេលដែលច្បាប់ស្តីពីកាតព្វកិច្ចយោធាមានជាធរមាន កងយោធពលខេមរភូមិន្ទ អាចធ្វើការជ្រើសរើសកំលាំងថ្មីបញ្ចូលជារៀងរាល់ឆ្នាំ ។ ការជ្រើសរើសទាហានថ្មី

ត្រូវឱ្យមានតុល្យភាពជាមួយនឹងចំនួនដែលត្រូវចាកចេញពីជួរកងទ័ព និងស្របទៅតាមគោលការណ៍ទាំងឡាយនៃការអនុវត្តន៍ច្បាប់ស្តីពីកាតព្វកិច្ចយោធា ។ គោលការណ៍នៃការអនុវត្តន៍ច្បាប់កាតព្វកិច្ចយោធាមានអធិប្បាយពិស្តារនៅផ្នែកខាងក្រោយនៃជំពូកនេះ ។



ឯកឧត្តម នាយឧត្តមសេនីយ មាស សុភា អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោកភូមិន្ទកម្ពុជា ប័ណ្ណសញ្ញាប័ត្រ ជំនាន់ ដល់កម្មសិក្សាការីវគ្គហ្វឹកហ្វឺនកុម្ម៉ង់ដូឆ័ត្រយោងជំនាន់ទី៤ ។

ការដាក់ពង្រាយកំលាំងទ័ព ត្រូវគិតគូរអំពីយុទ្ធសាស្ត្រយោធាដែលបានកំណត់រួចហើយ គឺការតបតប្រកបដោយភាពបត់បែន និងមានការត្រួតពិនិត្យ ។ នៅក្នុងន័យនេះ កងឯកភាពទ័ពស្រួច និងអន្តរាគមន៍ ត្រូវមានទីតាំងសមស្រប មានផ្លូវគមនាគមន៍ដើម្បីគាំទ្រដល់ការចល័តកំលាំង មានលទ្ធភាពធ្វើអន្តរាគមន៍បានទាន់ពេលវេលា និងមានអំណោយផលដល់ការរស់នៅ ការហ្វឹកហ្វឺន និងការបង្កបង្កើនផលផ្សេងៗ ។ ម្យ៉ាងទៀតត្រូវព្យាយាមលុបបំបាត់និន្នាការតំបន់និយម ។

នៅក្នុងពេលសន្តិភាព កំលាំងទ័ពស្រួចត្រូវតែទទួលបានការថែរក្សា និងបំប៉ន ។ ដូច្នេះការទទួលខុសត្រូវជាប្រចាំនៅតាមតំបន់ ត្រូវប្រគល់ទៅឱ្យកំលាំងតំបន់ប្រតិបត្តិការ

សឹករងរបស់បណ្តាខេត្ត-ក្រុង ។ កងយោធាថ្នាក់ស្រុក រួមជាមួយកងរាជអាវុធហត្ថ អាច បំពេញការងាររួមគ្នានៅក្នុងតំបន់ទទួលខុសត្រូវ ហើយចំពោះតំបន់ជួរមុខបំផុត ត្រូវប្រគល់ទៅឱ្យកងទ័ពការពារព្រំដែន ដោយសហការជាមួយតំបន់ប្រតិបត្តិការសឹករង និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត ។

## ការកែសំរួលរចនាសម្ព័ន្ធ និងការិយាធិបតេយ្យ:

រចនាសម្ព័ន្ធនៃកងយោធពលខេមរភូមិន្ទបច្ចុប្បន្ន ចាំបាច់ត្រូវតែមានការកែសំរួល តែទោះជាយ៉ាងណាក៏ដោយ ដំណើរការកែសំរួលរចនាសម្ព័ន្ធនេះ តំរូវអោយមានកិច្ចសហប្រតិបត្តិការ និងការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ស្ថាប័ន រាជរដ្ឋាភិបាលដែលពាក់ព័ន្ធទាំងឡាយ ។ម្យ៉ាងទៀត ការកែទំរង់កងយោធពលខេមរភូមិន្ទ ត្រូវតែដើរ *ស្របគ្នា និងមានតុល្យភាពជាមួយនឹងស្ថាប័នសន្តិសុខដទៃទៀត ។*

យើងសង្កេតឃើញថា ការកែទំរង់កងយោធពលខេមរភូមិន្ទ គឺជានយោបាយ និងការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ដែលមានស្ថាប័នរដ្ឋមួយចំនួនពាក់ព័ន្ធ ហើយទាមទារឱ្យមានកិច្ចសហការជាក់លាក់ទៅវិញទៅមករវាងស្ថាប័នរដ្ឋទាំងនោះ ។ អំណាចនៃក្រុមប្រឹក្សាកែទំរង់កងយោធពលខេមរភូមិន្ទបច្ចុប្បន្ន មិនបានគ្របដណ្តប់លើស្ថាប័នផ្សេងទៀត ក្រៅពីក្រសួងការពារជាតិឡើយ ។ ដូច្នេះ ដើម្បីបង្កើនប្រសិទ្ធិភាព និងរក្សាតុល្យភាពនៃការកែទំរង់ ក្រុមប្រឹក្សាកែទំរង់កងកំលាំងប្រដាប់អាវុធថ្នាក់ជាតិគឺជាស្ថាប័នដែលមានអំណាចគ្របដណ្តប់លើស្ថាប័នពាក់ព័ន្ធទាំងឡាយ ។

នៅក្នុងរយៈពេលកន្លងមកនេះ ដំណើរការកែទំរង់កងយោធពលខេមរភូមិន្ទបានជួបប្រទះនឹងឧបសគ្គដោយសារតែរចនាសម្ព័ន្ធនៃស្ថាប័នយោធា និងប្រព័ន្ធការងារ នៅមានភាពស្មុគ្រស្មាញនៅឡើយ ។ ការកែសំរួលរចនាសម្ព័ន្ធនៅតាមបណ្តាកងឯកភាពថ្នាក់ក្រោម បានទទួលជោគជ័យយ៉ាងត្រចះត្រចង់ ដោយបានធ្វើឱ្យអត្តសញ្ញាណនៃកងឯកភាពទាំងនោះ សមស្របទៅនឹងតំរូវការជាក់ស្តែង ព្រមទាំងបានបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងកំលាំងទ័ពផងដែរ ។ តែទោះជាយ៉ាងណាក៏ដោយ បំានានុក្រមថ្នាក់លើ ជា

ពិសេសរវាងក្រសួងការពារជាតិ អគ្គបញ្ជាការ និងបញ្ជាការដ្ឋានទ័ពទាំងបីប្រភេទ ទាមទារឱ្យមានការកែទំរង់ ។

## ការកែទំរង់វិស័យអប់រំហ្វឹកហ្វឺនៈ

ស្របតាមវិធានការដែលបានកំណត់ដោយសៀវភៅ ស ការពារជាតិ ឆ្នាំ២០០០ កងយោធពលខេមរភូមិន្ទបានប្រឹងប្រែងកែសំរួលប្រព័ន្ធហ្វឹកហ្វឺនយោធា បានយ៉ាងល្អប្រសើរ ក្នុងនោះមានការរៀបចំនូវលំដាប់ទាំងបីនៃការហ្វឹកហ្វឺនយោធិនអាជីព (ថ្នាក់នាយទាហានសកម្ម ថ្នាក់បញ្ជាការ និងសេនាធិការ និងការសិក្សាថ្នាក់យុទ្ធសាស្ត្រ) ។ ការអប់រំដោយឆ្លងកាត់តាមលំដាប់ទាំងបីនេះ នឹងធ្វើឱ្យនាយទាហានមានវិជ្ជាជីវៈផ្នែកយោធាពិតប្រាកដ មានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការបំពេញតួនាទី និងភារៈកិច្ចរបស់ខ្លួន មានជំនាញនៅក្នុងការដឹកនាំបញ្ជានៅក្នុងកងឯកភាព និងមានតំលៃគ្រប់គ្រាន់នៅក្នុងការចូលប្រឡូកជាមួយមជ្ឈដ្ឋានអន្តរជាតិ ។



*សកម្មភាពហ្វឹកហ្វឺន នៅសាលានាយទាហានរងកងទ័ពជើងគោក ពេជ្រនិល ។*

ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធអប់រំហ្វឹកហ្វឺនរបស់កងយោធពលខេមរភូមិន្ទបច្ចុប្បន្ន ទាមទារឱ្យមានការកែលំអបន្ថែមទៀត សំដៅធ្វើឱ្យថ្នាលបណ្តុះបណ្តាលធនធាន

មនុស្សកាន់តែមានប្រសិទ្ធិភាព និងប្រកបដោយគុណភាពឡើង ។ ក្រសួងការពារជាតិក្តី អគ្គបញ្ជាការក្តី ត្រូវរួមគ្នាពិចារណាលើទិដ្ឋភាពមួយចំនួនដូចខាងក្រោមៈ

- ការគ្រប់គ្រងស្ថាប័នអប់រំយោធិនអាជីព ស្ថិតនៅរាយប៉ាយនៅឡើយ ។ ដោយយោលទៅលើការលំបាកបច្ចុប្បន្ន និងដើម្បីបង្កើនប្រសិទ្ធិភាពនៅក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស អង្គភាពគ្រប់គ្រង និងដំណើរការវិស័យហ្វឹកហ្វឺន ត្រូវប្រមូលផ្តុំឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវតែមួយកន្លែង ។



*ឯកឧត្តម នាយឧត្តមសេនីយ ប៉ុល សារឿន អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ កំពុងត្រួតពិនិត្យការហ្វឹកហ្វឺនជំនាញដោះមីនរបស់កងឯកភាពវិស្វកម្ម ។*

- ក្រសួងការពារជាតិត្រូវស្វែងរកការគាំទ្រពីរាជរដ្ឋាភិបាល ក្នុងការលើកកំពស់អត្តសញ្ញាណរបស់ស្ថាប័នអប់រំយោធិនអាជីពមួយចំនួន ក្នុងគោលបំណងធ្វើឱ្យសមាមាត្រទៅនឹងប្រព័ន្ធអប់រំរបស់រដ្ឋ និងមានលក្ខណៈស្តង់ដាអន្តរជាតិ ។ វិទ្យាស្ថានយោធាកម្ពុជាឫស្សីកែវ នឹងត្រូវប្រែក្លាយឱ្យទៅជាសាកលវិទ្យាល័យការពារជាតិកម្ពុជា ។ ស្ថាប័នចំណុះក៏នឹងត្រូវរៀបចំឱ្យសមស្របផងដែរ ដូចជាមជ្ឈមណ្ឌលហ្វឹកហ្វឺនបញ្ជាការ និងសេនាធិការ

នឹងត្រូវតំឡើងទៅជាមហាវិទ្យាល័យបញ្ជាការ និងសេនាធិការ មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាបរទេស និងចំណេះដឹងទូទៅ និងមជ្ឈមណ្ឌលសិក្សាយុទ្ធសាស្ត្រ ទាំងពីរនេះត្រូវប្តូរទៅជាវិទ្យាស្ថានវិញ ។ ការកែសំរួលនេះ មិនត្រឹមតែលើកកំពស់វិស័យអប់រំនៅក្នុងវិស័យយោធាប៉ុណ្ណោះទេ តែនឹងត្រួសត្រាយផ្លូវសំរាប់ឱ្យប្រទេសកម្ពុជា អាចទទួលយកនិស្សិតយោធាបរទេសមកសិក្សាផងដែរ ។ ការផ្លាស់ប្តូរការសិក្សាផ្នែកយោធាទៅវិញទៅមកជាមួយបរទេស នឹងមិនអាចជៀសរួចបានទេ នៅក្នុងអនាគត ។



សកម្មភាពហ្វឹកហ្វឺន នៅសាលានាយទាហានរងកងទ័ពជើងគោក ពេជ្រនិល

- កម្មវិធីសិក្សាសំរាប់ស្ថាប័នអប់រំយោធិនអាជីពត្រូវតែធ្វើទំនើបកម្ម ដើម្បីឱ្យស្របជាមួយនឹងការវិវត្តន៍នៃបរិស្ថានអន្តរជាតិ និងការអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ ។ ស្ថាប័នដែលទទួលខុសត្រូវលើការងារអប់រំហ្វឹកហ្វឺនត្រូវខិតខំធ្វើឱ្យទាន់សម័យនូវកម្មវិធីសិក្សា ដោយសហការជាមួយនាយទាហានជំនាញៗ ដែលបានទទួលការអប់រំនៅបរទេស ឬអ្នកជំនាញ

ការបរទេសដែលកំពុងប្រចាំនៅកម្ពុជា ។ ការអភិវឌ្ឍន៍កម្មវិធីសិក្សានេះ នឹងជួយជំរុញឱ្យឆាប់មានលទ្ធភាព នៅក្នុងការផ្លាស់ប្តូរនិស្សិតយោធាជាមួយបរទេសផងដែរ ។



ឯកឧត្តម នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ប្រគល់ដាវប្រចាំដៃមាស ដល់ព្រឹមច្បងនៃសិស្សនាយទាហានសកម្ម ។

- ការពង្រីក សមត្ថភាពយោធាចារ្យ គឺជាកត្តាគន្លឹះនៅពេលដែលស្ថាប័ន និងកម្មវិធីសិក្សា ត្រូវបានលើកកំពស់ ។ ត្រូវជំរុញឱ្យយោធាចារ្យ សិក្សាភាសាអង់គ្លេសដែលជាមូលដ្ឋាន យ៉ាងសំខាន់នៅក្នុង ការសិក្សាខ្លួនឯងបន្ថែម និងមានលទ្ធភាពធ្វើការស្រាវជ្រាវ ចំណេះដឹងតាមរយៈ ប្រព័ន្ធពតិមានវិទ្យាផ្សេងៗ ។ នាយទាហានដែលបាន បញ្ចប់ការអប់រំយោធិនអាជីព នៅបរទេសត្រូវចំណាយពេល មួយរយៈនៅក្នុងស្ថាប័នអប់រំហ្វឹកហ្វឺន ដើម្បីចែករំលែកចំណេះដឹងរបស់ខ្លួន ឬក៏ចូលរួមនៅក្នុងការអភិវឌ្ឍន៍កម្មវិធីសិក្សា ។ អ្នកទទួលខុសត្រូវស្ថាប័នអប់រំយោធិនអាជីពនីមួយៗ ត្រូវព្យាយាមធ្វើទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅស្ថាប័នរបស់ខ្លួន ក្នុងការអញ្ជើញវាគ្មិនដែលមានបទពិសោធន៍ មកធ្វើបទឧទ្ទេសនាមនៅក្នុងកម្មវិធីសិក្សារបស់ខ្លួន ។

- កម្មវិធីសិក្សាសំរាប់សិស្សនាយទាហានសកម្ម ត្រូវបានពង្រីករហូតដល់រយៈពេល ៤ឆ្នាំ ។ ការពង្រីកកម្មវិធីនេះ មានបំណងធ្វើឱ្យការអប់រំមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងស្តង់ដាអន្តរជាតិ និងធ្វើឱ្យចំណេះដឹងរបស់នាយទាហានមានលំដាប់បរិញ្ញាប័ត្រ ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល ។ កំប៉ុន្តែ នៅក្នុងកាលៈទេសៈដែលកម្មវិធីសិក្សា និងសមត្ថភាពរបស់សាលាក្នុងការទទួលសិស្សនៅមានកំរិត ការសិក្សានៅក្នុងសាលានាយទាហានសកម្មគ្នាតពង ធ្វើត្រឹមតែរយៈពេល ៣ឆ្នាំ ចំណែកមួយឆ្នាំចុងក្រោយសិស្សនាយទាហានសកម្ម ត្រូវធ្វើការសិក្សាជំនាញឯកទេស នៅសាលានាយទាហានចំរុះថ្នាក់តាសេក ។ តែទោះជាយ៉ាងណាក៏ដោយ ការសិក្សារបស់សិស្សនាយទាហានសកម្មនៅតែមានរយៈពេល ៤ឆ្នាំដដែល ។
- សាលានាយទាហានរងកងទ័ពជើងគោកពេជ្រនិល ត្រូវប្តូរមកជាមជ្ឈមណ្ឌលហ្វឹកហ្វឺនកងទ័ពជើងគោក ។ មជ្ឈមណ្ឌលនេះមានតួនាទីសំខាន់ និងទូលំទូលាយនៅក្នុងការហ្វឹកហ្វឺនដល់កំលាំងថ្មី ។ មជ្ឈមណ្ឌលនេះ អាចប្រើប្រាស់ជាកន្លែងហ្វឹកហាត់យោធាខ្នាតកងវរសេនាតូចម៉ាំងមូលបានផងដែរ ។ ការហ្វឹកហ្វឺនបំប៉នតាមអង្គភាព អាចធ្វើនៅសាលាហ្វឹកហ្វឺននៅតាមភូមិភាគ ។
- ការយល់ដឹងអំពីនយោបាយការពារជាតិរបស់ព្រះរាជាណាចក្រកម្ពុជា គឺជាកត្តាសំខាន់សំរាប់យោធិនគ្រប់រូបក្នុងការអនុវត្តន៍តួនាទី និងភារកិច្ចរបស់ខ្លួន ដូចប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលតែងតែរំលឹកដាស់តឿនឱ្យប្រកាន់យកសៀវភៅ ស ការពារជាតិជាត្រៃវិស័យ ។ ការអប់រំអំពីនយោបាយការពារជាតិ ជាពិសេសអំពីគោលការណ៍ទាំងឡាយរបស់សៀវភៅ ស ការពារជាតិ ត្រូវតែធ្វើនៅគ្រប់ជំនាន់ក្រមរបស់កងទ័ពតាមរយៈការអប់រំផ្សព្វផ្សាយផ្ទាល់ដោយអ្នកជំនាញផ្នែកនេះ តាមរយៈ

ប្រព័ន្ធវិទ្យុទូរទស្សន៍ និងតាមរយៈឯកសារពាក់ព័ន្ធផ្សេងៗ ។ ការធ្វើសិក្ខាសាលា ឬសន្និបាត ដោយលើកយកគោលការណ៍យុទ្ធសាស្ត្រជាក់លាក់ម្តងមួយៗយកមកពិភាក្សា នឹងជួយជំរុញឱ្យការអនុវត្តន៍ជាក់ស្តែងនៃគោលការណ៍នោះ កាន់តែមានប្រសិទ្ធិភាព និងសំរេចគោលដៅ ។



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ និង ឯកឧត្តម ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា អញ្ជើញជាអធិបតីនៅក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អាគារមួយចំនួននៃសាលាហ្វឹកហ្វឺនអាវុធហត្ថកំបូល ដែលជាជំនួយឧបត្ថម្ភរបស់សាធារណរដ្ឋបារាំង ។

- បើសិនជាអាចធ្វើទៅបាននៅពេលអនាគត ប្រព័ន្ធឧបករណ៍ជំនួយ (ស៊ីមូឡេទ័រ) គួរយកមកប្រើប្រាស់នៅក្នុងការហ្វឹកហ្វឺន ដែលជាមធ្យោបាយជួយកាត់បន្ថយការចំណាយធនធាននៅក្នុងការហ្វឹកហ្វឺន ។

## ការកែទំរង់ប្រព័ន្ធភស្តុភារ-ហិរញ្ញវត្ថុ:

ការអនុវត្តនីវិធានការយុទ្ធសាស្ត្រណាក៏ដោយ សុទ្ធតែតំរូវឱ្យមានការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុជានិច្ច ។ ដោយហេតុថាយើងមានប្រព័ន្ធគ្រប់គ្រងធនធានការពារជាតិមិនសូវរឹងមាំ គួបផ្សំនឹងថវិកាមានកំរិត បានធ្វើឱ្យដំណើរការកែទំរង់មានការរអាក់រអួល និងអសកម្មនៅក្នុងវិស័យខ្លះ ។ វិធានការមួយចំនួនអាចត្រូវយកមកប្រើ នៅក្នុងការកែទំរង់នេះ:

- បង្កើតអាទិភាពនៃការចំណាយរៀងរាល់ឆ្នាំ ។ ការធ្វើបែបនេះនឹងធ្វើឱ្យមានការត្រៀមថវិកាសំរាប់ចំណាយ និងការចំណាយបានចំគោលដៅពិតប្រាកដ ។
- អនុញ្ញាតិឱ្យកងទ័ពមានសិទ្ធិធ្វើអាជីវកម្ម ជាពិសេសនៅលើវិស័យកសិ-ឧស្សាហកម្ម ដោយគោរពទៅតាមច្បាប់រដ្ឋ ។
- ធានាបើកត្រង់ដល់កងឯកភាព ដោយមានការផ្ទេរប្រគល់រវាងជំនាញរបស់ក្រសួង អគ្គបញ្ជាការ និងកងឯកភាពដែលត្រូវទទួល ។ កងឯកភាពដែលត្រូវទទួល ត្រូវផ្តល់ឱ្យបានគ្រប់គ្រាន់ទូវរបបដែលបានកំណត់ និងត្រូវមានការត្រួតពិនិត្យជាប់ជាប្រចាំ ។
- កាត់បន្ថយបទដ្ឋាននៃការធានាណាដែលមិនចាំបាច់ ដើម្បីកាត់បន្ថយការខ្ជះខ្ជាយ សន្សំពេលវេលា និងលើកស្ទួយតម្លាភាព ។

## ការលើកស្ទួយជីវភាពរបស់យោធិន:

ថវិកាការពារជាតិមានចំនួនស្តួចស្តើង បើប្រៀបធៀបទៅនឹងទំហំកងទ័ពដែលមានបច្ចុប្បន្ន ។ ស្ថានភាពថវិកាអាចនឹងប្រសើរឡើង នៅពេលណាមានការកាត់បន្ថយចំនួនទ័ពជាលំដាប់លំដោយ ។ តែទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលត្រូវតែរក្សាទំហំថវិកាការពារជាតិឱ្យមានស្ថិរភាពជានិច្ច នៅក្នុងពេលដែលក្រសួងការពារជាតិកំពុងកាត់បន្ថយចំនួនទ័ព ។ ថវិកាដែលបានមកពីការរំសាយទ័ព នឹងត្រូវយកទៅប្រើប្រាស់បន្ថែមនៅក្នុង:

- ការកសាងបន្ទាយទ័ព ។
- ការហ្វឹកហ្វឺន ។
- ការលើកស្ទួយជីវភាពរស់នៅរបស់យោធិន តាមរយៈការតម្លើងប្រាក់បៀវត្សឱ្យបានប្រហាក់ប្រហែលនឹងស្ថាប័នស៊ីវិលនានា ការជំរុញការផ្គត់ផ្គង់ជីវភាពដោយការ ចិញ្ចឹមសត្វ និងកសិកម្ម ផ្សេងៗទៀតជាដើម ។

- ពង្រឹកសេវាកម្មផ្នែកសុខមាលភាពនៅតាមយោធភូមិភាគ ឱ្យមានសមត្ថភាពផ្តល់ការគាំទ្រដល់យោធិន ក៏ដូចជាប្រជាពលរដ្ឋនៅក្នុងតំបន់ ។



ឯកឧត្តម ឧត្តមសេនីយ៍ឯក គង់ គីម អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ចូលរួមជាអធិបតី នៅក្នុងពិធីចុះសន្ធិសញ្ញាភាព-រវាងបញ្ជាការដ្ឋានការពារអាកាស ជាមួយនឹងអាជ្ញាធររដ្ឋបាលព្រៃឈើ ។

## ការថែទាំគ្រឿងយុទ្ធោបករណ៍:

ភាពទ្រុឌទ្រោមបន្តិចម្តងៗនៃគ្រឿងយុទ្ធោបករណ៍ គឺជាបញ្ហា និងជាឧបសគ្គសំរាប់ការពង្រឹងសមត្ថភាពកងកំលាំងប្រដាប់អាវុធ ។ កងយោធពលខេមរភូមិន្ទមានតួនាទីចំបងនៅក្នុងការការពារអធិបតេយ្យភាព និងបូរណភាពទឹកដី ។ គ្រឿងយុទ្ធោបករណ៍គឺជាមធ្យោបាយដ៏សំខាន់មួយ នៅក្នុងការកសាងសមត្ថភាពយោធាឱ្យបានរឹងប៉ឹង ដើម្បីធានាដល់ការឆ្លើយតបឱ្យបានជាវិជ្ជមានចំពោះកិច្ចការពារជាតិមាតុភូមិ ។ ជាការពិតណាស់ នៅពេលណាដែលយើងមានកំលាំង និងសមត្ថភាពគ្រប់គ្រាន់ ការរំលោភបំពានពីខាងក្រៅ ប្រាកដជានឹងសាបសូន្យទៅដែរ ។

នៅក្នុងកាលៈទេសៈដែលរាជរដ្ឋាភិបាលកំពុងជួបការលំបាក នៅក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិនាពេលបច្ចុប្បន្ន លទ្ធកម្មសំភារៈយោធាថ្មីៗពុំងាយអាចធ្វើទៅបាន

ទេ ។ ដូច្នេះមធ្យោបាយចំបងដើម្បីដោះស្រាយបញ្ហានេះ គឺការថែទាំឱ្យបានខ្ជាប់ខ្ជួននូវសំភារៈយោធាដែលមានក្នុងពេលបច្ចុប្បន្ន ។ អាទិភាពនៃកិច្ចការពារជាតិនៅពេលនេះគឺផ្តោតការយកចិត្តទុកដាក់លើកិច្ចការពារព្រំដែនគោក និងការពង្រឹងសន្តិសុខដែនសមុទ្រដែលតំរូវឱ្យកងយោធាមានវត្តមាន និងមានសមត្ថភាពធ្វើសកម្មភាពជាប្រចាំ ។

ក្រសួងការពារជាតិ អគ្គបញ្ជាការ រួមទាំងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរត្រូវរួមគ្នាដោះស្រាយបញ្ហានេះ ធ្វើយ៉ាងណាបង្កលក្ខណៈឱ្យមានការជួសជុលជាបន្ទាន់ នូវសំភារៈធំៗមួយចំនួនដូចជា នាវា រថក្រោះ កាំភ្លើងធំ យន្តហោះ និងមធ្យោបាយដឹកជញ្ជូនដទៃទៀត ។ ក្រោយការជួសជុល ត្រូវយកចិត្តទុកដាក់បន្តការថែទាំសំភារៈទាំងនេះឱ្យដំណើរការបានជានិច្ច ។ មេបញ្ជាការកងឯកភាពត្រូវប្រើប្រាស់សំភារៈរបស់ខ្លួនឱ្យបានចំគោលដៅ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។



កងទ័ពអាកាសភូមិន្ទកម្ពុជា យកចិត្តទុកដាក់ជាប្រចាំ នៅក្នុងការថែទាំសំភារៈគ្រឿងយុទ្ធោបករណ៍ ទោះជាក្នុងស្ថានភាពជួបប្រទះនឹងការខ្វះខាតផ្នែកធនធានក៏ដោយ ។

សៀវភៅ ស ការពារជាតិ ឆ្នាំ២000 បានរំលឹករួចមកហើយអំពីស្មារតីថ្លៃប្រឌិតដែលអាចធ្វើបាន នៅក្នុងវិស័យខ្លះនៃការប្រើប្រាស់សំភារៈសឹក ជាពិសេសនៅក្នុងវិស័យដឹកជញ្ជូន ការចល័តកំលាំង ការទាក់ទង...ល ។ ការប្រើប្រាស់សំភារៈស៊ីវិលនៅក្នុងវិស័យ

យោធា អំណោយផលសំរាប់លទ្ធកម្ម ការជួសជុលថែទាំ និងការរកគ្រឿងបន្លាស់ ។ លើសពីនេះទៅទៀត ការប្រើប្រាស់មានភាពងាយស្រួល ហើយការជួសជុលអាចធ្វើបាននៅរោងជាងរបស់កងទ័ព និងរោងជាងនានានៅស្ទើរគ្រប់ទីកន្លែងផងដែរ ។ ឧទាហរណ៍ជាក់ស្តែង រថយន្តតួយូតាមួយចំនួនកំពុងត្រូវបានប្រើប្រាស់ដោយកងរាជអាវុធហត្ថ សំរាប់ការចល័តកំលាំង និងការធ្វើសកម្មភាព ។ មធ្យោបាយនៃការបញ្ជូនសារក៏ដូចគ្នាដែរ ជំនួសឱ្យការប្រើប្រាស់សំភារៈបញ្ជូនសារយោធា វិទ្យុទាក់ទងស៊ីវិល ទូរស័ព្ទ ទូរសារ ប្រព័ន្ធអ៊ីមែលក៏ជាជំរើសដ៏ប្រសើរសំរាប់ការបញ្ជូនពត៌មាន ។ លទ្ធភាពនៃការថែទាំសំភារៈតាមកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន ក៏គួរយកមកពិចារណាផងដែរ ។



*យុទ្ធជននៃកងយោធពលខេមរភូមិន្ទរៀបចំទុកដាក់អាវុធយុទ្ធភ័ណ្ឌ នៅក្នុងឃ្លាំងសុវត្ថិភាព ដែលកសាងឡើងនៅក្រោមកិច្ចសហការជាមួយកម្មវិធី EU-ASAC ។*

ព្រឹត្តិការណ៍ផ្ទុះឃ្លាំងគ្រាប់នៅខេត្តបាត់ដំបងកាលពីដើមឆ្នាំ២០០៥ គឺជាមេរៀនមួយដែលត្រូវតែមានការគិតគូរឱ្យបានហ្មត់ចត់អំពីសុវត្ថិភាពនៃឃ្លាំងស្តុកសំភារៈសឹក ។ កងយោធពលខេមរភូមិន្ទត្រូវតែបង្កើនស្មារតីទទួលខុសត្រូវថែមទៀត លើការថែរក្សាសំភារៈ អាវុធ គ្រាប់រំសេវ ដោយការពង្រឹងសុវត្ថិភាពនៅតាមកន្លែងស្តុក ។ លើសពីនេះ

ទៅទៀត ត្រូវត្រួតពិនិត្យឡើងវិញនូវគុណភាពគ្រាប់រំសេវទាំងនោះ ហើយបើចាំបាច់ត្រូវធ្វើការបំផ្លាញចោល ដើម្បីជៀសវាងគ្រោះថ្នាក់ជាយថាហេតុ ។

ទោះជាយ៉ាងណាក៏ដោយ កិច្ចខំប្រឹងប្រែងដើម្បីស្វែងរកជំនួយពីខាងក្រៅ នៅតែជាការចាំបាច់មួយ សំរាប់ការស្រោចស្រង់ភាពទ្រុឌទ្រោមនៃសំភារៈយោធាសំខាន់ៗ ។ ក្រសួងការពារជាតិ ក៏ដូចជាអគ្គបញ្ជាការ ត្រូវខិតខំពង្រីកកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យនេះជាមួយប្រទេសជាមិត្ត ឱ្យបានទូលំទូលាយថែមទៀត ជាពិសេសនៅក្នុងការកសាងរ៉ោអូសនាវានៅមូលដ្ឋានរាម រោងជាងកងទ័ពជើងគោក រោងជាងកងទ័ពជើងអាកាស និងសមត្ថភាពផ្នែកបញ្ជូនសារ ជាដើម ។

## បន្ទាយទ័ព:

បន្ទាយគឺជាមូលដ្ឋានយ៉ាងសំខាន់សំរាប់គ្រប់គ្រង និងដឹកនាំបញ្ជាកំលាំងនៅតាមបណ្ដាកងឯកភាពឱ្យបានខ្ជាប់ខ្ជួន និងមានប្រសិទ្ធិភាព ។ បន្ទាយផ្ដល់នូវភាពងាយស្រួលក្នុងការប្រមូលផ្ដុំ ការគ្រប់គ្រង ការចល័តកំលាំង ការហ្វឹកហ្វឺន ការរស់នៅ ការពង្រឹងវិន័យ និងសីលធម៌ ការផ្ដល់សេវាសុខភាព...ល ។

នៅក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ ការកសាងបន្ទាយទ័ពឱ្យបានសមរម្យបានជួបប្រទះនឹងការលំបាកយ៉ាងខ្លាំង ដោយសារបញ្ហាកង្វះខាតថវិកា ។ ការតស៊ូឱ្យមានស្ថានភាពដូចបច្ចុប្បន្ន បានមកដោយសារស្មារតីឆ្នៃប្រឌិតរបស់កងឯកភាពមូលដ្ឋាន ការបរិច្ចាគរបស់សប្បុរសជន និង ការជួយឧបត្ថម្ភពីក្រសួងការពារប្រទេសនៃសាធារណរដ្ឋប្រជាមានិតចិន ក៏ប៉ុន្តែពុំទាន់មាននិយាមគ្រប់គ្រាន់សំរាប់បំរើឱ្យការគ្រប់គ្រងទ័ពនៅឡើយទេ ។ ក្រសួងការពារជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិគ្រោះគ្នា ដើម្បីរកវិធីដោះស្រាយបញ្ហានេះ ហើយថវិកាទាំងឡាយណាដែលបានមកពីការកាត់រំសាយទ័ពត្រូវទុកជូនក្រសួងការពារជាតិ ដើម្បីយកទៅដោះស្រាយការកសាងបន្ទាយទ័ពនេះ ។

## កិច្ចប្រឹងប្រែងជួយខ្លួនឯង:

កន្លងមករាជរដ្ឋាភិបាលបានផ្ដល់លទ្ធភាពខ្លះៗហើយ សំរាប់កងយោធពលខេមរភូមិន្ទ ដើម្បីធ្វើការអភិវឌ្ឍន៍ និងឧបត្ថម្ភដល់អង្គភាពរបស់ខ្លួន ជាពិសេសតាមរយៈតំបន់



*ឯកឧត្ដម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី (ខាងឆ្វេង) និងឯកឧត្ដម នាយឧត្ដមសេនីយ កែ គឹមយ៉ាន អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ (ខាងស្ដាំ) ចុះហត្ថលេខាលើសម្ព័ន្ធមេត្រីភាព រវាងទីស្ដីការគណៈរដ្ឋមន្ត្រី ជាមួយនឹងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ។*

អភិវឌ្ឍន៍មួយចំនួន ។ ក្រៅពីការដាំដំណាំ និងចិញ្ចឹមសត្វ នៅតាមអង្គភាព ការស្វែងរកការវិនិយោគនៅលើតំបន់អភិវឌ្ឍន៍ដែលបានប្រគល់ឱ្យ មានសារៈសំខាន់ណាស់ ។ នៅពេលណាដែលមានការខិតខំទាក់ទាញវិនិយោគដើម្បីផលប្រយោជន៍រួម និងប្រកបដោយគណនេយ្យភាព ដៃគូវិនិយោគអាចជាក្រុមហ៊ុនឯកជនក្នុងស្រុក ឬក្រុមហ៊ុនបរទេស ។ ម្យ៉ាងវិញទៀត ដីធ្លីដែលជាទីតាំង និងតំបន់អភិវឌ្ឍន៍របស់កងទ័ព ត្រូវតែមានការចុះបញ្ជីកម្មសិទ្ធឱ្យបានច្បាស់លាស់ ប្រយោជន៍ដើម្បីជំរះមន្ទិលសំរាប់ការវិនិយោគ និងដើម្បីជៀសវាងទំនាស់ដីធ្លីជាមួយអ្នកស្រុក និងមជ្ឈដ្ឋានផ្សេងទៀត តទៅថ្ងៃអនាគត ។

ក៏ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៅទៀត គឺការលើកទឹកចិត្តឱ្យកងយោធាមានសិទ្ធ និងលទ្ធភាព នៅក្នុងការធ្វើអាជីវកម្មខ្នាតមធ្យម ដើម្បីរកកំរៃឧបត្ថម្ភខ្លួន និងកសាងអង្គភាព ។ រាជរដ្ឋាភិបាលក៏បានចេញសេចក្ដីសំរេចរួចមកហើយដែរ អំពីការបង្កើតសម្ព័ន្ធមេត្រីភាពរវាងអង្គភាពនៃកងយោធពលខេមរភូមិន្ទ ជាមួយនឹងស្ថាប័នរដ្ឋមួយ

ចំនួន ដែលតាមរយៈសម្ព័ន្ធភាពនេះ អង្គភាពយោធាអាចនឹងបានទទួលការឧបត្ថម្ភគាំទ្រពីសំណាក់ស្ថាប័នរដ្ឋទាំងនោះ នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីអភិវឌ្ឍជីវភាពរស់នៅរបស់ខ្លួន ។

## បច្ចេកវិទ្យាពត៌មាន:

ការវិវត្តន៍នៃកិច្ចការផ្នែកយោធា មានដំណើរលឿនទៅមុខយ៉ាងឆាប់រហ័សនៅក្នុងប៉ុន្មានទសវត្សកន្លងមកនេះ ។ យុគសម័យកុំព្យូទ័រ បានធ្វើឱ្យការគ្រប់គ្រង ការដឹកនាំបញ្ជា កិច្ចប្រតិបត្តិការ ការទាក់ទង និងការអភិវឌ្ឍន៍កំលាំង របស់កងយោធានៅលើពិភពលោក ត្រូវពឹងផ្អែកលើបច្ចេកវិទ្យាទំនើបកាន់តែច្រើនឡើង ហើយការប្រើប្រាស់កំលាំងមនុស្សកាន់តែថយចុះ ។



*នាយទាហាននៃកងយោធពលខេមរភូមិន្ទកំពុងទទួលបានការហ្វឹកហ្វឺនជំនាញកុំព្យូទ័រ នៅនាយកដ្ឋាននយោបាយ និងផែនការ ក្រសួងការពារជាតិ ។*

បច្ចេកវិទ្យានៅកម្ពុជាក្នុងពេលបច្ចុប្បន្ន មានការជឿនលឿនទៅមុខគួរឱ្យកត់សំគាល់ ។ កងយោធពលខេមរភូមិន្ទអាចកេងយកប្រយោជន៍អំពីការប្រើប្រាស់បច្ចេកវិទ្យាទំនើប ដូចជាកុំព្យូទ័រ ប្រព័ន្ធអ៊ីម៉ែល អ៊ិនធ័រណេត... ល ដើម្បីជាមធ្យោបាយប្រកប

ដោយប្រសិទ្ធិភាព និងទាន់ពេលវេលា សំរាប់ដំណើរការនៅទីបញ្ជាការ ការដឹកនាំបញ្ជា ការទាក់ទង ការសិក្សាស្រាវជ្រាវ ជាដើម ។ នាយទាហានគ្រប់រូបត្រូវទទួលស្គាល់អំពីសារៈសំខាន់នៃបច្ចេកវិទ្យា ហើយខិតខំយកចិត្តទុកដាក់កសាងចំណេះដឹងនៅក្នុងវិស័យនេះ ជាពិសេសចំណេះដឹងផ្នែកភាសាអង់គ្លេស ដែលជាការចាំបាច់នៅក្នុងការប្រើប្រាស់សំភារៈបានត្រឹមត្រូវ ។ លើសពីនេះទៅទៀត ចំណេះដឹង និងការមាននូវសមត្ថភាពទាំងនេះ នឹងធ្វើឱ្យមានភាពងាយស្រួលក្នុងការទំនាក់ទំនងជាអន្តរជាតិ ជាពិសេសសំរាប់ការចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាព ក៏ដូចជាការអប់រំហ្វឹកហ្វឺននៅបរទេសផងដែរ ។

## កិច្ចប្រតិបត្តិការជួយសង្គ្រោះ:

ការថមថយនៃព្រៃធម្មជាតិ រួមផ្សំនឹងដំណើរប្រែប្រួលនៃអាកាសធាតុផែនដី បានធ្វើឱ្យ ប្រទេសកម្ពុជាជួបប្រទះ នឹងគ្រោះធម្មជាតិ ស្ទើររៀងរាល់ឆ្នាំ ។ ទឹកជំនន់ និងគ្រោះរាំងស្ងួត គឺជាបញ្ហាចំបង ។ កន្លងមក កងយោធពលខេមរភូមិន្ទ គឺជាកំលាំង យ៉ាងសំខាន់នៅក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋនៅពេលជួបវិបត្តធម្មជាតិ ដូចជាការទប់ទឹកតាមច្រាំងទន្លេ និងស្ទឹងនានា ការជម្លៀសអ្នករងគ្រោះទៅកាន់តំបន់មានសុវត្ថិភាព ផ្តល់ការរក្សាសន្តិសុខ និងការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត ជាដើម ។



*សកម្មភាពរបស់អាវុធហត្ថ ក្នុងការទប់ទល់ការពារទឹកជំនន់ នៅខេត្តកំពង់ចាម ។*

កងយោធពលខេមរភូមិន្ទមានកំលាំងសមល្មមហើយ នៅក្នុងការបំពេញភារកិច្ចនេះ ។ កំលាំងទាំងនោះរួមមានកងកំលាំងពិសេស កងរាជអាវុធហត្ថ កងវិស្វកម្ម កងទ័ព

ជើងគោក កងទ័ពជើងទឹក និងកងទ័ពជើងអាកាស ។ ក្រៅពីការស្វែងរកសំភារៈបន្ថែម ដែលត្រូវធ្វើជាមួយដៃគូបរទេស កងយោធាត្រូវការនូវសមត្ថភាពសំខាន់មួយ ទៀតដែលអាចធ្វើឱ្យការបំពេញភារកិច្ចមានប្រសិទ្ធិភាព និងទាន់ពេលវេលា គឺការត្រៀមលក្ខណៈជា



*ការត្រៀមលក្ខណៈជួយសង្គ្រោះប្រជាពលរដ្ឋនៅពេលជួបគ្រោះធម្មជាតិ របស់កងកំលាំងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ ។*

ប្រចាំ ។ ការត្រៀមលក្ខណៈជាប្រចាំនេះ តំរូវឱ្យកងឯកភាពដែលពាក់ព័ន្ធមានកំលាំងមនុស្សដែលត្រូវប្រតិបត្តិការ មានសំភារៈអាចដំណើរការបាន មានមធ្យោបាយ និងយុទ្ធវិធីនៅក្នុងការបំពេញភារកិច្ច ។ ជាការប្រសើរ កងឯកភាពដែលពាក់ព័ន្ធទាំងឡាយ រួមទាំងស្ថាប័នស៊ីវិលផង ត្រូវបង្កើតឱ្យមានការធ្វើសមយុទ្ធរួមគ្នាអំពីកិច្ចប្រតិបត្តិការជួយសង្គ្រោះ យ៉ាងហោចណាស់មួយឆ្នាំម្តង ដើម្បីធ្វើឱ្យការឆ្លើយតបទៅនឹងសភាពការណ៍ជាក់ស្តែង បានទាន់ពេលវេលា និងមានប្រសិទ្ធិភាព ។ លើសពីនេះទៅទៀត ក្រសួងការពារជាតិ និងអគ្គបញ្ជាការ គួរពិចារណាអំពីការរៀបចំសមត្ថភាពសំរាប់ក្រុមតូច ដែលអាចចេញទៅប្រតិបត្តិការជួយសង្គ្រោះនៅក្រៅប្រទេស នាពេលអនាគត ។

### តំរូវការគ្របដណ្តប់ច្បាប់:

ទោះបីរាជរដ្ឋាភិបាលមានច្បាប់ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ មួយចំនួនសំរាប់ពង្រឹងដល់កងយោធពលខេមរភូមិន្ទក៏ដោយ ប៉ុន្តែយើងនៅតែពុំមានច្បាប់គ្រប់គ្រាន់សំរាប់បំរើឱ្យវិស័យកងទ័ពនៅឡើយទេ ។ ដូចនេះ ចាំបាច់ត្រូវរៀបចំច្បាប់ថ្មីមួយចំនួនទៀត ហើយច្បាប់ចាស់ដែលមានស្រាប់ ក៏ចាំបាច់ត្រូវធ្វើវិសោធនកម្មដើម្បីឆ្លើយតបទៅតាមការវិវត្តន៍នៃសភាពការណ៍នៅក្នុងសង្គមជាតិ និងនៅលើឆាកអន្តរជាតិ ។

**ភាពចាំបាច់សំរាប់ការរៀបចំច្បាប់ថ្មី (អំពីកាតព្វកិច្ចយោធា):** ចាប់តាំងពីឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្នមានរយៈពេលជាង១០ឆ្នាំហើយ ប៉ុន្តែច្បាប់កាតព្វកិច្ចយោធា ឬក៏ច្បាប់អ្វីដែលជំរុញឱ្យមានកាតព្វកិច្ចការពារមាតុភូមិ ពុំទាន់បានបង្កើតឡើងដើម្បីឱ្យប្រជាពលរដ្ឋយល់ដឹងអំពីកាតព្វកិច្ចរបស់ខ្លួនចំពោះជាតិ និងពិសេសការជ្រើសរើសយោធិនថ្មីនៅឡើយទេ ។ ការអនុវត្តន៍ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ បានធ្វើឱ្យមានកំណើននាយទាហានកាន់តែច្រើនឡើងៗ ចំណែកពលទាហានកាន់តែថយចំនួនតិចទៅៗ ដែលជាហេតុនាំឱ្យពលទាហាន និងនាយទាហានរបស់យើងពុំមានតុល្យភាពនឹងគ្នាឡើយ ។ ឧទាហរណ៍ជាក់ស្តែង នៅក្នុងរបាយការណ៍របស់កងទ័ពជើងគោកនៅក្នុងសិក្ខាសាលាបូកសរុបលទ្ធផលការងារ ៥ឆ្នាំ បានបង្ហាញឱ្យឃើញថា ចំនួននាយទាហានមានចំនួនរហូតដល់ទៅ ៧៧ភាគរយ ។

ដូច្នេះដើម្បីធ្វើការកែទំរង់កងយោធពលខេមរភូមិន្ទរបស់យើង ឱ្យសក្តិសមជាកំលាំងស្នូលក្នុងការការពារជាតិ ការពារបូរណៈភាពដែនដី និងកិច្ចប្រតិបត្តិការផ្សេងៗទៀត គឺមានតែច្បាប់កាតព្វកិច្ចយោធាមួយប៉ុណ្ណោះ ដែលអាចដោះស្រាយចំពោះបញ្ហានេះបាន ។ ពិតមែនតែកាតព្វកិច្ចយោធា គឺជាផ្នែកមួយនៃការពង្រឹងនីតិរដ្ឋ ព្រោះជាយន្តការដ៏ពិសិដ្ឋដើម្បីឱ្យប្រជាពលរដ្ឋ ភ្ញាក់រលឹកអនុវត្តន៍នូវកាតព្វកិច្ចរបស់ខ្លួនក្នុងបុព្វហេតុការពារមាតុភូមិ និងមានឱកាសបានបំពេញភារកិច្ចដ៏ចាំបាច់ ក្នុងឋានៈជាពលរដ្ឋមានកិត្តិយស និងបានសំដែងនូវសុឆន្ទៈជាក់ស្តែងចំពោះមាតុភូមិរបស់ខ្លួនក៏ដោយ ការ

អនុវត្តន៍ច្បាប់នេះបន្ទាប់ពីសភាបានអនុម័តរួចហើយ ត្រូវមានការថ្លឹងថ្លែងទៅតាមសភាពការណ៍ជាក់ស្តែង ដូចជា:

**ក្នុងពេលសន្តិភាព:** ថ្វីត្បិតតែច្បាប់នេះមានលក្ខណ:ជាកាតព្វកិច្ច តែការអនុវត្តន៍ជាក់ស្តែងគឺផ្អែកទៅលើតំរូវការប៉ុណ្ណោះ ។ តាមការព្យាករណ៍ នៅក្នុងរយ:ពេល ៥ឆ្នាំខាងមុខ កងយោធពលខេមរភូមិន្ទត្រូវការបុគ្គលិកថ្មី ផ្អែកទៅតាមសមតុល្យនៃការបញ្ចេញទ័ពក្នុងឆ្នាំនីមួយៗ ។

**ក្នុងពេលមានវិបត្តិ:** ប្រទេសជាតិអាចត្រូវការទាហានថ្មីច្រើនជាងនេះ នៅក្នុងពេលដែលប្រទេសជាតិជួបប្រទះវិបត្តផ្សេងៗ រាប់បញ្ចូលទាំងវិបត្តគ្រោះធម្មជាតិធំៗផងដែរ ។ តែទោះជាយ៉ាងណាក៏ដោយ ការអនុវត្តន៍ត្រូវតែស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់ជាដរាប ។

**ក្នុងពេលមានសង្គ្រាម:** ច្បាប់ស្តីពីកាតព្វកិច្ចយោធាត្រូវតែអនុវត្តន៍មួយរយភាគរយ និងម៉ឺងម៉ាត់បំផុត ដើម្បីឆ្លើយតបទៅនឹងស្ថានភាពប្រទេសមានអាសន្ន ។ នៅក្នុងកាល:ទេស:បែបនេះ អាចតំរូវឱ្យមានការអនុវត្តន៍លើសពីនេះ រហូតដល់មានកំណែនទូទៅទៀតផង ។

ក៏ប៉ុន្តែការបង្កើតច្បាប់ស្តីពីកាតព្វកិច្ចយោធា កំពុងចោទជាកង្វល់លើការយល់ច្រឡំមួយចំនួន ។ ដូច្នេះយើងត្រូវការនូវកិច្ចខិតខំប្រឹងប្រែងគ្រប់រូបភាព ដើម្បីចាត់វិធានការ និងធ្វើការអប់រំផ្សព្វផ្សាយដល់សាធារណជន ឱ្យជ្រួតជ្រាបអំពីច្បាប់នេះ ដូចជា:

- បំបាត់នូវកង្វល់ ឬការភ័យខ្លាច ដែលថាវាជាការចាប់បង្ខំយុវជន យុវនារីឱ្យបំពេញការងារមួយដែលគ្មានជំរើស ពុំនោះសោតទេគេនឹងត្រូវទទួលទោសទណ្ឌកម្ម ។
- កាតព្វកិច្ចយោធា មិនត្រូវឱ្យក្លាយជាសកម្មភាពមួយប៉ះពាល់ដល់ការអភិវឌ្ឍន៍ធនធានមនុស្ស ឬការបណ្តុះបណ្តាលវិជ្ជាជីវ:ដល់យុវជនឡើយ ។
- បញ្ហានយោបាយ និងសកម្មភាពគណបក្សនយោបាយ ត្រូវនៅឱ្យឆ្ងាយពីកាតព្វកិច្ចយោធា ។

- ត្រូវទប់ស្កាត់អំពើពុករលួយ ឬការឆ្លៀតប្រើប្រាស់កាតព្វកិច្ចយោធា ដើម្បីបំរើផលប្រយោជន៍បុគ្គល ។

ក្រៅពីកាតព្វកិច្ចយោធា កងយោធពលខេមរភូមិន្ទត្រូវពិចារណាលើការបង្កើតប្រព័ន្ធកំលាំងបំរុង ដែលជាប្រភពកំលាំងថ្មីដ៏សំខាន់បំផុតតទៅថ្ងៃអនាគត ។ ការបង្កើតកំលាំងបំរុង កំពុងត្រូវបានប្រើប្រាស់នៅបណ្តាប្រទេសមួយចំនួនធំ ព្រោះវាជាវិធានការមានប្រសិទ្ធិភាពសំរាប់ការផ្លាស់ប្តូរកំលាំងនៅជូរកងទ័ព ចំណាយតិច ហើយមានប្រជាពលរដ្ឋច្រើនឡើងៗដែលចេះវិជ្ជាជីវៈយោធាដែលជាទុនដ៏ប្រសើរសំរាប់តំរូវការពេលស្រុកមានវិបត្តិ ។ នៅពេលដែលការផ្គត់ផ្គង់ជីវភាពកងទ័ពបានប្រសើរឡើង ការជ្រើសរើសយោធាបំរុងនឹងត្រូវធ្វើឡើងដោយការស្ម័គ្រចិត្ត ហើយជៀសវាងបាននូវផលវិបាកផ្សេងៗទៀតផង ។ នៅពេលណាដែលកំលាំងសកម្មរបស់កងយោធពលខេមរភូមិន្ទខ្វះខាតកំលាំង យោធិនបំរុងអាចត្រូវបានជ្រើសរើសឱ្យចូលជាកំលាំងសកម្មបាន ។ ប្រព័ន្ធកំលាំងបំរុង អាចនឹងត្រូវបានអនុវត្តនៅក្រោមច្បាប់ស្តីពីកាតព្វកិច្ចយោធា ដោយត្រូវការឱ្យមានបញ្ញត្តិបន្ថែមមួយចំនួន ។ ម្យ៉ាងទៀត យើងអាចសន្សំថវិកាបានច្រើននៅពេលដែលយើងមានប្រព័ន្ធនេះ ដូចជាការចំណាយលើប្រាក់បៀវត្ស ការហ្វឹកហ្វឺន និងការធានាជីវភាពជាច្រើនមុខទៀត ។

ជំរើសមួយទៀតសំរាប់ធ្វើឱ្យកងយោធពលខេមរភូមិន្ទ កាន់តែអាចទុកចិត្តបានមានការបត់បែន និងសន្សំសំចៃ គឺការផ្តួចផ្តើមឱ្យមានយោធិនក្រោមកិច្ចសន្យា ដែលមានរយៈពេលពី២ ទៅ ២០ឆ្នាំ ។ យោធិនក្រោមកិច្ចសន្យាអាចត្រូវគេជ្រើសរើយកមកសំរាប់ពេលវេលាមួយ ហើយត្រូវចាកចេញបន្ទាប់ពីបានបំពេញនូវករណីយកិច្ចរបស់គេ ដោយគ្មានសិទ្ធិតាមផ្លូវច្បាប់បានទទួលនូវប្រាក់ចូលនិវត្តន៍ណាមួយ ក្រៅពីប្រាក់បំណាច់បន្តិចបន្តួចប៉ុណ្ណោះ ។

**ការពង្រឹងច្បាប់បន្ថែម:** ដើម្បីពង្រឹងជំហរកងយោធពលខេមរភូមិន្ទ នៅក្នុងរដ្ឋប្រកបដោយប្រជាធិបតេយ្យ ការគ្រប់ដណ្តប់ផ្នែកច្បាប់ទៅលើភារៈកិច្ចប្រចាំថ្ងៃ ក៏ដូចជាវិន័យយោធា ត្រូវតែធ្វើការអភិវឌ្ឍ ដូចជាក្រមវិន័យកងទ័ព ច្បាប់ស្តីពីតុលាការយោធា

ច្បាប់ស្តីពីការស៊ើបអង្កេតពីសភាជាវិធានការចុងក្រោយ ដើម្បីដោះស្រាយរាល់បញ្ហាដែលកើតមាន រវាងយោធិន និងមេបញ្ជាការ ក្របខ័ណ្ឌច្បាប់ដ៏សំខាន់ មួយសំរាប់ឧទ្ទរណ៍ផ្នែកយោធាដែលជួយធានាដល់សិទ្ធិរបស់យោធិនគ្រប់រូប និងក្របខ័ណ្ឌច្បាប់សំរាប់កិច្ចប្រតិបត្តិការអន្តរជាតិ ជាដើម ។

## កិច្ចសហប្រតិបត្តិការអន្តរជាតិ:

អនុលោមទៅតាមគោលដៅយុទ្ធសាស្ត្រនៃកិច្ចការពារជាតិ ដែលបានអធិប្បាយនៅក្នុងជំពូកទី ៣ រួចមកហើយ កងយោធពលខេមរភូមិន្ទនឹងបង្កើនការយកចិត្តទុកដាក់នៅក្នុងការពង្រីកកិច្ចសហប្រតិបត្តិការយោធាជាមួយបណ្តាប្រទេសជាមិត្តទាំងឡាយ ។ កិច្ចសហប្រតិបត្តិការយោធាដែលទាមទារឱ្យមានការលើកស្ទួយទាំងនេះ ត្រូវធ្វើនៅក្នុងគោលជំហរមិនប្រកាន់និន្នាការនយោបាយ ឬមនោគមន៍វិជ្ជា និងឈរលើស្មារតីគោរពផលប្រយោជន៍គ្នាទៅវិញទៅមក ។ កងយោធពលខេមរភូមិន្ទក្នុងពេលបច្ចុប្បន្ន ក៏ដូចជាអនាគតរយៈពេលខ្លី និងមធ្យមខាងមុខ ត្រូវការជាចាំបាច់នូវការគាំទ្រពីសំណាក់អន្តរជាតិ



*ឯកឧត្តម ព្រឹទ្ធសមាជិក Robert Hill រដ្ឋមន្ត្រីក្រសួងការពារជាតិអូស្ត្រាលី ត្រូវបានទទួលស្វាគមន៍ដោយថ្នាក់ដឹកនាំក្រសួងការពារជាតិកម្ពុជា និងនាយទាហានជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ នៅក្នុងឱកាសធ្វើទស្សនកិច្ចនៅកម្ពុជា កាលពីខែមេសា ឆ្នាំ២០០៥*

នៅក្នុងវិស័យសំខាន់ៗមួយចំនួន ដើម្បីទ្រទ្រង់ដល់ដំណើរការកែទំរង់កងយោធារបស់ខ្លួន ។ វិស័យសំខាន់ៗទាំងនោះមានជាអាទិ៍:

- ការបណ្ដុះបណ្ដាលធនធានមនុស្ស នៅក្នុងចំណោមបុគ្គលិកយោធាថ្នាក់ប្រតិបត្តិការ និងថ្នាក់យុទ្ធសាស្ត្រ ។




ឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ឹង សំផន (រូបកណ្ដាល) រដ្ឋលេខាធិការក្រសួងការពារជាតិ អញ្ជើញជាអធិបតីក្នុងពិធីផ្ទេរប្រគល់អាគារពិគ្រោះជំងឺទូទៅកំពស់ ៥ជាន់ ដែលជាអំណោយរបស់សាធារណរដ្ឋប្រជាមានិតចិន ជូនដល់មន្ទីរពេទ្យយោធា ព្រះកេតុមាលា ។

- ការពង្រឹងសមត្ថភាពការពារព្រំដែន ជាពិសេសសមត្ថភាពឯកទេសមួយចំនួនសំរាប់ទប់ស្កាត់ និងបង្ក្រាប ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់រូបភាព ។
- សមត្ថភាពរឹងប៉ឹងនៅក្នុងការទប់ស្កាត់ និងប្រឆាំងអំពើភេរវកម្ម ។
- លទ្ធភាពរបស់កងយោធាកាន់តែទូលំទូលាយថែមទៀត នៅក្នុងការបំពេញភារកិច្ចក្នុងពេលសន្តិភាព (វិស្វកម្ម ការដោះមីន កិច្ចប្រតិបត្តិការជួយសង្គ្រោះ និងកិច្ចប្រតិបត្តិការមនុស្សធម៌ផ្សេងៗទៀត) ។
- ការបង្កើនសមត្ថភាពនាយទាហាននៅក្នុងការយល់ដឹងផ្នែកច្បាប់ ។

- ការជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនសមត្ថភាពប្រតិបត្តិការរបស់កងទ័ពជើងទឹក ជាពិសេសការធ្វើឱ្យគ្រឿងយុទ្ធោបករណ៍របស់កងទ័ពជើងទឹកសំខាន់ៗមួយចំនួនអាចប្រតិបត្តិការបាន ។
- ការអភិវឌ្ឍន៍ចំណេះដឹងផ្នែកភាសាបរទេស និងពត៌មានវិទ្យា ។

ចាប់តាំងពីឆ្នាំ១៩៩៣មក កិច្ចសហប្រតិបត្តិការយោធាជាមួយបរទេសមានការរីកចំរើនជាលំដាប់ ជាពិសេសនៅក្នុងវិស័យបណ្តុះបណ្តាលធនធានមនុស្ស និងជំនួយផ្នែកបច្ចេកទេសផ្សេងៗទៀត ។ តែទោះជាដូច្នេះក្តី កង្វះខាតនៅក្នុងការសំរបសំរួលដ៏ជាក់លាក់មួយលើកម្មវិធីនៃកិច្ចសហប្រតិបត្តិការយោធាទាំងអស់ បានធ្វើឱ្យដំណើរការផ្តល់ជំនួយនៅពេលខ្លះផ្តុំគ្នាតែទៅលើវិស័យមួយៗ ។ម្យ៉ាងទៀតក៏រិតធនធានរបស់ម្ចាស់ជំនួយ និងការផ្សាភ្ជាប់ជំនួយទៅនឹងហេតុផលនយោបាយ បានធ្វើឱ្យកម្មវិធីនៃកិច្ចសហប្រតិបត្តិការយោធាខ្លះត្រូវរាំងស្ទះ ឬក៏ពុំមានលក្ខណៈជាដុំកំភួន ។

## សមត្ថភាពក្នុងកិច្ចប្រតិបត្តិការរក្សាសន្តិភាព:

បច្ចុប្បន្ននេះ ក៏ដូចជាតទៅអនាគត កងយោធពលខេមរភូមិន្ទកំពុងតែប្រឹងប្រែងនៅក្នុងការកសាងកិត្យានុភាពរបស់ខ្លួននៅលើឆាកអន្តរជាតិ ។ តួនាទីនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព គឺជាលទ្ធភាពមួយដែលកងយោធពលខេមរភូមិន្ទអាចរួមចំណែក នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងសន្តិភាព និងសន្តិសុខនៅក្នុងតំបន់ និងនៅពាសពេញពិភពលោក ។

កងយោធពលខេមរភូមិន្ទ ត្រូវបានគិតគូរអំពីការបង្កើនសមត្ថភាពមួយចំនួនសំរាប់រួមចំណែកនៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិផងដែរ ។ ដោយមានសំណូមពរពីសំណាក់អង្គការសហប្រជាជាតិ កងយោធពលខេមរភូមិន្ទបានចូលរួមនៅក្នុងបេសកកម្មសន្តិភាពរបស់អង្គការសហប្រជាជាតិនៅទ្វីបអាហ្រ្វិក នៅក្នុងផ្នែកពីរសំខាន់ៗ គឺការដោះ

មីន និងអ្នកសង្កេតការយោធា ។ នាយទាហានសង្កេតការខ្មែរមួយចំនួន និងកងអនុសេនាធំដោះមីន កំពុងតែបំពេញបេសកកម្មរបស់ខ្លួននៅប្រទេសស៊ូដង់ ។ ក្រៅពី



សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រគល់ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ជូនដល់មេបញ្ជាការកងអនុសេនាធំដោះមីនលេខ១៣៥ សំរាប់បេសកកម្មសន្តិភាព និងមនុស្សធម៌ នៅប្រទេសស៊ូដង់ ។

នេះ កងយោធពលខេមរភូមិន្ទ នៅមានសមត្ថភាពពិសេសមួយចំនួនទៀត ដែលអាចយកទៅប្រើប្រាស់បាននៅក្នុងបេសកកម្មដូចនេះ មានជាអាទិ៍ វិស្វកម្ម ពេទ្យសង្គ្រោះបន្ទាន់ ប៉ូលីសស៊ីវិល ជាដើម ។

តែទោះជា យ៉ាងណាក៏ដោយ ដើម្បីលើកស្ទួយសមត្ថភាពទាំងនេះ ឱ្យកាន់តែមានប្រសិទ្ធិភាពឡើង ទាមទារឱ្យមាន នូវកិច្ចសហប្រតិបត្តិការ និងការជួយជ្រោមជ្រែង ពីសំណាក់ប្រទេសជាមិត្ត ដែលមានបទពិសោធន៍ ។



ការធ្វើដំណើរចាកចេញរបស់យុទ្ធជននៃកងអនុសេនាធំដោះមីនលេខ១៣៥ ឆ្ពោះទៅកាន់ប្រទេសស៊ូដង់ កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ។

គណៈកម្មាធិការសំរបសំរួលកិច្ចការបញ្ជូនកំលាំង ចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ បានត្រូវបង្កើតឡើងក្នុងឋានៈជាយន្តការថ្នាក់ជាតិ ដើម្បីធ្វើការសំរបសំរួល និងទំនាក់ទំនងជាមួយអង្គការសហប្រជាជាតិ ព្រមទាំងជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា ។ មជ្ឈមណ្ឌលមួយក៏ត្រូវតែរៀបចំឡើងដែរ ដើម្បីធ្វើការបណ្តុះបណ្តាលធនធានមនុស្សសំរាប់បេសកកម្មរក្សាសន្តិភាព ។ វិទ្យាស្ថានយោធាកម្ពុជា គឺជាកន្លែងសមរម្យសំរាប់ការអប់រំហ្វឹកហ្វឺន ហើយការអនុវត្តន៍កម្មវិធី អាចធ្វើឡើងដោយមានកិច្ចសហការពីប្រទេសជាមិត្តដែលស្ម័គ្រចិត្ត ។



ឯកឧត្តម នាយឧត្តមសេនីយ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រគល់ឯកសារណែនាំដល់មេបញ្ជាការ កងអនុសេនាធំដោះមីនលេខ១៣៥ មុនពេលចេញដំណើរទៅបំពេញបេសកកម្មមនុស្សធម៌ នៅប្រទេសស៊ូដង់ ។

# ជំពូកទី ៥
# យន្តការនៃអភិបាលកិច្ច

ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រឱ្យបានសំរេចគោលដៅជាស្ថាពរ ទាមទារឱ្យមានការប្តេជ្ញាចិត្តមុះមុត សមត្ថភាពក្នុងការដឹកនាំ រចនាសម្ព័ន្ធដែលអាចដំណើរការបាន ការគ្រប់គ្រងហ្មត់ចត់ និងធនធានសមស្រប ។ ការខ្វះការយល់ដឹងអំពីនយោបាយការពារជាតិ រួមផ្សំនឹងកង្វះកិច្ចសហការពីសំណាក់ស្ថាប័នពាក់ព័ន្ធ អាចធ្វើឱ្យការអនុវត្តន៍គោលការណ៍យុទ្ធសាស្ត្រទាំងឡាយរបស់សៀវភៅ ស ការពារជាតិនេះ មិនបានសំរេចគោលដៅទាំងស្រុង ។ ដូច្នេះ កត្តាមួយចំនួនដូចខាងក្រោម ត្រូវលើកយកមកពិចារណា ក្នុងគោលបំណងធ្វើឱ្យមានការធានាដល់ជោគជ័យ នៃផែនការយុទ្ធសាស្ត្រដែលបានកំណត់ពីខាងដើម ។

## គម្លាភាព:

អភិបាលកិច្ចល្អ ដែលជាគោលការណ៍ចំបងរបស់រាជរដ្ឋាភិបាល ទាមទារនូវតម្លាភាព ។ យ៉ាងណាមិញ គោលដៅយុទ្ធសាស្ត្រទាំងឡាយដែលមានចែងនៅក្នុងសៀវភៅ ស ការពារជាតិនេះ ពឹងផ្អែកទាំងស្រុងទៅលើការពង្រឹងតម្លាភាពនៅក្នុងការអនុវត្តន៍ ។ ការគាំទ្រសំខាន់មួយទៀត គឺប្រព័ន្ធច្បាប់យោធា ។ តំរូវការនៃការពង្រឹងច្បាប់បន្ត ដែលបានអធិប្បាយនៅក្នុងជំពូកទី ៤ នឹងមិនត្រឹមតែធ្វើឱ្យស្របទៅតាមបទដ្ឋានអន្តរជាតិប៉ុណ្ណោះទេ តែក៏ជាតំរូវការចាំបាច់សំរាប់យោធិនម្នាក់ៗ ផងដែរ ។

នៅក្នុងរយៈពេលជាង ១០ឆ្នាំមកនេះ កងយោធពលខេមរភូមិន្ទមានគោលបំណងធំមួយ គឺរៀបចំខ្លួនឱ្យក្លាយទៅជាកងទ័ពអាជីព និងមានគុណភាពខ្ពស់ ។ បើប្រៀបធៀបទៅនឹងកត្តាពេលវេលា ឃើញថាមានរយៈពេលយូរមកហើយដែរ ហើយយើងនៅពុំទាន់បានសំរេចគោលដៅនៅឡើយ ។ ថ្វីបើមានការរីកចំរើនមួយចំនួនធំរួចមក

គណកម្មាធិការសំរបសំរួលកិច្ចការបញ្ជូនកំលាំង ចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ បានត្រូវបង្កើតឡើងក្នុងថានៈជាយន្តការថ្នាក់ជាតិ ដើម្បីធ្វើការសំរបសំរួល និងទំនាក់ទំនងជាមួយអង្គការសហប្រជាជាតិ ព្រមទាំងជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា ។ មជ្ឈមណ្ឌលមួយក៏ត្រូវតែរៀបចំឡើងដែរ ដើម្បីធ្វើការបណ្តុះបណ្តាលធនធានមនុស្សសំរាប់បេសកកម្មរក្សាសន្តិភាព ។ វិទ្យាស្ថានយោធាកម្ពុជា គឺជាកន្លែងសមរម្យសំរាប់ការអប់រំហ្វឹកហ្វឺន ហើយការអនុវត្តន៍កម្មវិធី អាចធ្វើឡើងដោយមានកិច្ចសហការពីប្រទេសជាមិត្តដែលស្ម័គ្រចិត្ត ។



ឯកឧត្តម នាយឧត្តមសេនីយ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រគល់ឯកសារណែនាំដល់មេបញ្ជាការកងអនុសេនាធំដោះមីនលេខ១៣៥ មុនពេលចេញដំណើរទៅបំពេញបេសកកម្មមនុស្សធម៌ នៅប្រទេសស៊ូដង់ ។

# ជំពូកទី ៩
# យន្តការនៃអភិបាលកិច្ច

ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រឱ្យបានសំរេចគោលដៅជាស្ថាពរ ទាមទារឱ្យមានការប្តេជ្ញាចិត្តមុះមុត សមត្ថភាពក្នុងការដឹកនាំ រចនាសម្ព័ន្ធដែលអាចដំណើរការបានការគ្រប់គ្រងហ្មត់ចត់ និងធនធានសមស្រប ។ ការខ្វះការយល់ដឹងអំពីនយោបាយការពារជាតិ រួមផ្សំនឹងកង្វះកិច្ចសហការពីសំណាក់ស្ថាប័នពាក់ព័ន្ធ អាចធ្វើឱ្យការអនុវត្តន៍គោលការណ៍យុទ្ធសាស្ត្រទាំងឡាយរបស់សៀវភៅ ស ការពារជាតិនេះ មិនបានសំរេចគោលដៅទាំងស្រុង ។ ដូច្នេះ កត្តាមួយចំនួនដូចខាងក្រោម ត្រូវលើកយកមកពិចារណា ក្នុងគោលបំណងធ្វើឱ្យមានការធានាដល់ជោគជ័យ នៃផែនការយុទ្ធសាស្ត្រដែលបានកំណត់ពីខាងដើម ។

## តម្លាភាព:

អភិបាលកិច្ចល្អ ដែលជាគោលការណ៍ចំបងរបស់រាជរដ្ឋាភិបាល ទាមទារនូវតម្លាភាព ។ យ៉ាងណាមិញ គោលដៅយុទ្ធសាស្ត្រទាំងឡាយដែលមានចែងនៅក្នុងសៀវភៅ ស ការពារជាតិនេះ ពឹងផ្អែកទាំងស្រុងទៅលើការពង្រឹងតម្លាភាពនៅក្នុងការអនុវត្តន៍ ។ ការគាំទ្រសំខាន់មួយទៀត គឺប្រព័ន្ធច្បាប់យោធា ។ តំរូវការនៃការពង្រឹងច្បាប់បន្ត ដែលបានអធិប្បាយនៅក្នុងជំពូកទី ៤ នឹងមិនត្រឹមតែធ្វើឱ្យស្របទៅតាមបទដ្ឋានអន្តរជាតិប៉ុណ្ណោះទេ តែក៏ជាតំរូវការចាំបាច់សំរាប់យោធិនម្នាក់ៗ ផងដែរ ។

នៅក្នុងរយៈពេលជាង ១០ឆ្នាំមកនេះ កងយោធពលខេមរភូមិន្ទមានគោលបំណងធំមួយ គឺរៀបចំខ្លួនឱ្យក្លាយទៅជាកងទ័ពអាជីព និងមានគុណភាពខ្ពស់ ។ បើប្រៀបធៀបទៅនឹងកត្តាពេលវេលា ឃើញថាមានរយៈពេលយូរមកហើយដែរ ហើយយើងនៅពុំទាន់បានសំរេចគោលដៅនៅឡើយ ។ ថ្វីបើមានការរីកចំរើនមួយចំនួនធំរួចមក

ហើយក្តី ចំណុចអសកម្មមួយចំនួនបានបន្ទុចបង្អាក់ ឬធ្វើឱ្យយឺតយ៉ាវដល់ដំណើរការកែទំរង់ ដែលនៅក្នុងចំណោមចំណុចទាំងនោះ ក៏មានរួមបញ្ចូលទាំងការគ្រប់គ្រងបុគ្គលិកផងដែរ ។ មេដឹកនាំគ្រប់ជាន់ថ្នាក់ ត្រូវចាប់ផ្តើមជាបន្ទាន់នូវការលុបបំបាត់ឱ្យបានជាស្ថាពរ រាល់ការគ្រប់គ្រងកំលាំងទ័ពមិនទាន់ប្រកបដោយតម្លាភាពទាំងឡាយ មានរាប់បញ្ចូលទាំងបញ្ហាទាហានខ្មោចផងដែរ ។ នៅក្នុងពេលដែលកងយោធពលខេមរភូមិន្ទកំពុងជួបប្រទះនឹងបញ្ហាអតិផរណានាយទាហានជាន់ខ្ពស់ ក្រសួងការពារជាតិ និងអគ្គបញ្ជាការត្រូវយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហានេះ ដោយធ្វើឱ្យមាននូវយន្តការត្រួតពិនិត្យឱ្យបានល្អិតល្អន់ និងប្រកបដោយតម្លាភាពថែមទៀត នូវរាល់ការតម្លើងឋានន្តរសក្តិនាយទាហាន ។ ការតម្លើងឋានន្តរសក្តិ ឬការផ្តល់ឥស្សរយស ត្រូវធ្វើទៅតាមតំរូវការពិតប្រាកដ ទៅតាមក្រឹត្យក្រមនៃច្បាប់ ជៀសវាងបក្សពួកនិយម និងខិតខំលើកស្ទួយតំលៃនៃរង្វាន់ទាំងនោះ ។ ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ ជាពិសេសក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ត្រូវសហការជាមួយក្រសួងការពារជាតិឱ្យជិតស្និតថែមទៀតនៅក្នុងការរិះរកវិធីធ្វើឱ្យការអនុវត្តន៍ច្បាប់សោធននិវត្តន៍មានប្រសិទ្ធិភាព ដែលអាចឱ្យយើងរំលោះនាយទាហានដែលដល់ពេលចូលនិវត្តន៍មួយបានចំនួនធំ ។

ថវិកាការពារជាតិមានកំរិតស្តួចស្តើងណាស់ បើប្រៀបធៀបទៅនឹងទំហំកងទ័ពនាពេលបច្ចុប្បន្ន ។ យើងសង្ឃឹមថាការរក្សាទំហំថវិកាសំរាប់កិច្ចការពារជាតិឱ្យនៅស្ថេរសំរាប់កងទ័ពដែលមានទំហំតូចជាងនេះនៅពេលអនាគត នឹងជួយសំរួលដល់កិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យកងយោធពលខេមរភូមិន្ទក្លាយជាកងទ័ពមានអាជីព និងប្រកបដោយគុណភាព ។ តែទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ធនធានដ៏ស្តួចស្តើងនេះ ឱ្យមានតម្លាភាព គឺជាការចាំបាច់ ។ ការកសាងតម្លាភាពនេះ ទាមទារឱ្យមានការគ្រប់គ្រងការចំណាយ និងចំណូល ឱ្យបានហ្មត់ចត់ ។ ការចំណាយសព្វបែបយ៉ាង ដាច់ខាតត្រូវផ្អែកលើអាទិភាពនៃការចំណាយ ដែលបានកំណត់រួចហើយ យោលទៅលើភាពចាំបាច់ប្រចាំឆ្នាំ ។

## ការឃ្លាំមើលលើការជឿនលឿនទៅមុខ:

ការបង្កើតនូវគោលការណ៍យុទ្ធសាស្ត្រមិនមែនជាការលំបាកប៉ុន្មានទេ ប៉ុន្តែអ្វីដែលសំខាន់ជាអាយុជីវិតនោះគឺការការអនុវត្តន៍ ។ ដូច្នេះ ដើម្បីធានាដល់ការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលលើវិស័យការពារជាតិ ឱ្យបានជាវិជ្ជមាន និងប្រកបដោយជោគជ័យ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធត្រូវតែយល់ច្បាស់អំពីគោលដៅយុទ្ធសាស្ត្ររបស់សៀវភៅ ស ការពារជាតិ ពុំនោះសោតទេ ពិតជាបង្កឱ្យមានការមិនយោគយល់គ្នា ភាពអសកម្ម និងបរាជ័យជាយថាហេតុ ជាក់ជាមិនខាន ។




*ឯកឧត្តម នាយឧត្តមសេនីយ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ (រូបកណ្ដាលជួរមុខ) អញ្ជើញជាអធិបតីនៅក្នុងពិធីបិទសិក្ខាសាលាសៀវភៅ ស ការពារជាតិ ស្ដីពីការគ្រប់គ្រងបុគ្គលិក និងការរៀបចំកំលាំងបំរុង ដែលធ្វើឡើងនៅទីក្រុងសៀមរាប កាលពីខែមិថុនា ឆ្នាំ២០០៥ ។ សិក្ខាសាលានេះមានកិច្ចសហការពីក្រសួងការពារជាតិអូស្ត្រាលី ។*

ជាការពិតណាស់ គ្រប់ឋានានុក្រមទាំងអស់នៃកងយោធពលខេមរភូមិន្ទ ក៏ចាំបាច់ត្រូវតែមានការយល់ដឹងច្បាស់លាស់អំពីគោលការណ៍យុទ្ធសាស្ត្រទាំងឡាយ ដែលមាននៅក្នុងសៀវភៅ ស ការពារជាតិនេះដែរ ។ ក្រសួងការពារជាតិត្រូវចាត់ឱ្យក្រុមជំនាញសៀវភៅ ស ការពារជាតិ ចុះផ្សព្វផ្សាយការយល់ដឹងអំពីនយោបាយការពារជាតិ ឱ្យបានគ្រប់មជ្ឈដ្ឋានទាំងអស់នៅក្នុងជួរកងយោធពលខេមរភូមិន្ទ រួមទាំងនៅតាមស្ថាប័នអប់រំហ្វឹកហ្វឺនយោធាផងដែរ ។ ការផ្សព្វផ្សាយនេះត្រូវធ្វើឱ្យបានដូចភ្លៀងរលឹម ។ ក្រៅពីសៀវភៅ ស ការពារជាតិ ក្រុមជំនាញគប្បី ស្វែងរកឧបករណ៍បន្ថែមទៀត ដូចជាកូន

សៀវភៅសង្ខេបខ្លឹមសារ ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិច ជាដើម នៅក្នុងយុទ្ធនាការផ្សព្វផ្សាយ សំដៅបង្កើនភាពងាយស្រួលដល់ការយល់ដឹង ។

សៀវភៅ ស ការពារជាតិ បានកំណត់នូវវិធានការយុទ្ធសាស្ត្រច្រើនណាស់សំរាប់កងយោធពលខេមរភូមិន្ទយកទៅអនុវត្តន៍ ។ ការអត្ថាធិប្បាយសំរាប់វិធានការនីមួយៗភាគច្រើនមានលក្ខណៈទូលំទូលាយ ។ ដូច្នេះនៅក្នុងការអនុវត្តន៍ជាក់ស្តែង ទាមទារឱ្យមានការរៀបចំផែនការលំអិតបន្ថែមទៀត ។ ដើម្បីជាជំនួយ និងជាទុន នៅក្នុងការរៀបចំផែនការសកម្មភាព ក្រសួងការពារជាតិ និងអគ្គបញ្ជាការត្រូវបន្តរៀបចំឱ្យមានជាសិក្ខាសាលា ឬសន្និបាត ដោយជ្រើសយកវិធានការយុទ្ធសាស្ត្រម្តងមួយៗ មកធ្វើការបកស្រាយឱ្យបានស៊ីជំរៅ ។ បើអាចធ្វើទៅបាន ការពិភាក្សាគួរធ្វើការកំណត់តារាងពេលវេលាសំរាប់ការអនុវត្តនីវិធានការនីមួយៗ ។ ទស្សនៈផ្សេងៗដែលផុសចេញពីការពិភាក្សា អាចបានជាអនុសាសន៍ដ៏ប្រសើរសំរាប់ក្រសួងការពារជាតិ និងអគ្គបញ្ជាការ ក្នុងការធ្វើឱ្យបានសំរេចជោគជ័យនូវការអនុវត្តន៍នយោបាយការពារជាតិរបស់រាជរដ្ឋាភិបាល ។ កិច្ចការនេះត្រូវការឱ្យមានការជួយជ្រោមជ្រែងពីសំណាក់ក្រសួងដែលពាក់ព័ន្ធទាំងឡាយ និងដៃគូបរទេសផងដែរ ។

ក្រសួងការពារជាតិ ក៏ដូចជាអគ្គបញ្ជាការ ត្រូវធ្វើការវិនិច្ឆ័យលទ្ធផលនៃការអនុវត្តនីវិធានការយុទ្ធសាស្ត្រ តាមរយៈយន្តការនៃការត្រួតពិនិត្យជាប្រចាំ ។ ក្រុមការងារអនុវត្តន៍គោលការណ៍សៀវភៅ ស ការពារជាតិ ដែលបានបង្កើតកាលពីឆ្នាំ២០០២ នៅមានជាធរមាននៅឡើយ ក្រុមការងារនេះធ្លាប់បានបំពេញនូវភារកិច្ចរបស់ខ្លួនបានយ៉ាងល្អប្រសើរ ដូចជាសកម្មភាពទាំងឡាយដែលនាំឆ្ពោះទៅរកការបង្កើតឯកសារវិវេចនាលើយុទ្ធសាស្ត្រការពារជាតិ ឆ្នាំ២០០២ ជាដើម ។ ដូច្នេះក្រុមការងារនេះអាចបន្តពង្រីកការងាររបស់ខ្លួនតទៅទៀត នៅក្នុងការតាមឃ្លាំមើលការអនុវត្តន៍គោលការណ៍របស់សៀវភៅ ស ការពារជាតិ ឆ្នាំ២០០៦ នេះ ។ ក្រុមការងារនេះត្រូវផ្តួចផ្តើមឱ្យមានវិធីសាស្ត្របន្ថែមទៀតនៅក្នុងការឃ្លាំមើលនេះ ដូចជារៀបចំសិក្ខាសាលា ឬសន្និបាត ការ

បង្កើតឱ្យមានរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តន៍ ការផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តន៍ តាមរយៈប្រព័ន្ធពត៌មាន (វិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដីកងទ័ព) ជាដើម ។

## ការទទួលខុសត្រូវចំពោះការអនុវត្តន៍:

រាល់ការអនុវត្តន៍វិធានការយុទ្ធសាស្ត្រ ទាមទារឱ្យមានការទទួលខុសត្រូវជានិច្ច ទៅតាមតួនាទីរៀងៗខ្លួន ។ មេបញ្ជាការកងឯកភាព មេបញ្ជាការយោធភូមិភាគ មេបញ្ជាការប្រភេទទ័ព ...ល ត្រូវយកចិត្តទុកដាក់ជាប្រចាំ នៅក្នុងការត្រួតពិនិត្យលើការអនុវត្តន៍វិធានការដែលជាបន្ទុករបស់ខ្លួន ហើយត្រូវខិតខំឱ្យអស់ពីសមត្ថភាព ដើម្បីរិះរកវិធីដោះស្រាយរាល់ផលវិបាក និងភាពអសកម្មទាំងឡាយណា ដែលបង្កការរាំងស្ទះដល់ការសំរេចបេសកកម្ម ។ ក្រសួងការពារជាតិត្រូវខិតខំបង្កលក្ខណៈផ្តល់នូវមធ្យោបាយដែលអាចធ្វើទៅរួច ដល់អង្គភាពថ្នាក់ក្រោម ដើម្បីបង្កើតឱ្យមានលទ្ធភាពកាន់តែច្រើនឡើងនៅក្នុងការសំរេចជោគជ័យ ។ ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ដែលជាប្រភពដ៏សំខាន់មួយ សំរាប់ធានាដល់និរន្តរភាពនៃការសំរេចគោលដៅ ត្រូវបង្កើនការយកចិត្តទុកដាក់ចំពោះការលំបាកទាំងឡាយ ដែលកងយោធពលខេមរភូមិន្ទកំពុងជួបប្រទះ ។ ស្ថាប័ននេះត្រូវស្វែងយល់ឱ្យបានច្បាស់អំពីឫសគល់ និងភាពពិតនៃបញ្ហា ហើយជួយរិះរកអនុសាសន៍ និងវិធីដោះស្រាយឱ្យបានឆាប់រហ័សទាន់ពេលវេលា ដោយសហការឱ្យបានជិតស្និតជាមួយក្រសួងការពារជាតិ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ។ ឈរលើស្មារតីនៃកិច្ចសហប្រតិបត្តិការជិតស្និតរវាងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ កងយោធពលខេមរភូមិន្ទពិតជាមានលទ្ធភាពអាចសំរេចភារៈកិច្ចបានយ៉ាងល្អប្រសើរ និងប្រកបដោយភាពរលូនជាក់ជាមិនខាន ។

## ក្រុមការងារសៀវភៅ ស ការពារជាតិ

| | |
|---|---|
| ឧត្តមសេនិយឯក **នាង ផាត** | ប្រធាន |
| ឧត្តមសេនិយឯក **ហ៊ុន ភឿង** | សមាជិក |
| ឧត្តមសេនិយឯក **ជា សារ៉ន** | សមាជិក |
| ឧត្តមសេនិយឯក **ណើម សុវត្ថិ** | សមាជិក |
| ឧត្តមសេនិយឯក **ផន ណារ៉ា** | សមាជិក |
| ឧត្តមសេនិយឯក **លី ដេត** | សមាជិក |
| ឧត្តមសេនិយទោ **សួន សំណាង** | សមាជិកអចិន្ត្រៃយ៍ |
| ឧត្តមសេនិយទោ **ម៉ឹម សុផាត** | សមាជិក |
| ឧត្តមនារីទោ **សៅ សារិន** | សមាជិក |
| ឧត្តមសេនិយទោ **គង់ មុនី** | សមាជិក |
| ឧត្តមសេនិយទោ **តេង ឈួន** | សមាជិក |

*ការបោះពុម្ពឯកសារនេះ ទទួលបានការឧបត្ថម្ភពីក្រសួងការពារជាតិ*
*នៃប្រទេសអូស្ត្រាលី និងមូលនិធិ ហ្វ្រីឌ្រិច ណៅម៉ាន់ នៃប្រទេសអាល្លឺម៉ង់ ។*